ប្រើប្រាស់ឯកសារបណ្តុះបណ្តាលដែលបានសហការបង្កើតឡើងដោយក្រុមអ្នកជំនាញអន្តរវិស័យ មកពីប្រទេសថៃ និងម៉ាឡេស៊ី ដោយធានាឱ្យបាននូវភាពពាក់ព័ន្ធ និងប្រសិទ្ធភាព។

គោលបំណងចម្បងនៃគម្រោងនេះ រួមមាន ការលើកកម្ពស់សមត្ថភាពធ្វើបរិវត្តកម្មឌីជីថលនៅក្នុងគ្រឹះស្ថានឧត្តមសិក្សានៅទូទាំងអាស៊ីអាគ្នេយ៍ ដែលចំណុចនេះមានពាក់ព័ន្ធនឹងការបង្កើតផែនការយុទ្ធសាស្ត្រឌីជីថលដ៏រឹងមាំ និងការកែលម្អទិដ្ឋភាពផ្សេងៗនៃគុណភាពសិក្សា វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រគរុកោសល្យដើម្បីសម្របខ្លួនទៅនឹងទិដ្ឋភាពឌីជីថល។ លទ្ធផលសំខាន់ៗនៃគម្រោង រួមមាន ផែនការ និងគោលនយោបាយបរិវត្តកម្មឌីជីថលនៅតាមគ្រឹះស្ថានឧត្តមសិក្សា ធនធានបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយ និងកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល (ToT) តាមជំនាញឯកទេស ដែលមានគោលដៅពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ICT និងប្រព័ន្ធគ្រប់គ្រងការសិក្សាតាមប្រព័ន្ធឌីជីថលនៅសាកលវិទ្យាល័យ។ ជាងនេះទៅទៀត គំនិតផ្តួចផ្តើមនេះសង្កត់ធ្ងន់ទៅលើការពង្រឹងភាពស្ទាត់ជំនាញក្នុងការបង្កើតមាតិកាឌីជីថលសម្រាប់ការផ្តល់ការអប់រំ ក៏ដូចជាការជំរុញភាពស្ទាត់ជំនាញក្នុងការបង្រៀនឌីជីថល ការវាយតម្លៃ ការតាមដាន និងការធានាគុណភាព។

គម្រោងនេះ ប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវពហុទិដ្ឋភាពដើម្បីប្រមូលទិន្នន័យគ្រប់ជ្រុងជ្រោយអំពីបរិវត្តកម្មឌីជីថលនៅតាមគ្រឹះស្ថានឧត្តមសិក្សានៅទូទាំងអាស៊ីអាគ្នេយ៍។ ជាដំបូង គេបានធ្វើការពិនិត្យមើលឯកសារមានស្រាប់យ៉ាងទូលំទូលាយត្រូវបានធ្វើឡើងដើម្បីវិភាគលើឯកសារសិក្សា របាយការណ៍ និងអត្ថបទសិក្សាទាក់ទងនឹងនិន្នាការ និងបច្ចេកវិទ្យានៃបរិវត្តកម្មឌីជីថលនៅក្នុងតំបន់នេះ។ លើសពីនេះទៀត ទម្រង់ស្ទង់មតិក៏បានផ្តល់ជូនភាគីពាក់ព័ន្ធសំខាន់ៗ រួមទាំង បុគ្គលិករដ្ឋបាលសាកលវិទ្យាល័យ សាស្ត្រាចារ្យ និងនិស្សិត ក្នុងគោលបំណងប្រមូលធាតុចូលអំពីការអនុវត្តបច្ចុប្បន្ន បញ្ហាប្រឈម និងបំណងប្រាថ្នាពាក់ព័ន្ធឌីជីថលនីយកម្មក្នុងថ្នាក់អប់រំឧត្តមសិក្សា។ បន្ថែមពីលើនេះទៅទៀត ការសម្ភាសន៍ស៊ីជម្រៅក៏បានធ្វើឡើងជាមួយអ្នកជំនាញក្នុងវិស័យនេះ ដើម្បីប្រមូលធាតុចូល និងទស្សនៈកាន់តែស៊ីជម្រៅអំពីប្រធានបទនេះផងដែរ។ បច្ចេកទេសវិភាគទិន្នន័យផ្សេងៗ ដែលរួមបញ្ចូលទាំង វិធីសាស្ត្របែបគុណភាព និងបែបបរិមាណ ត្រូវបានគេប្រើប្រាស់ដើម្បីវិភាគការឆ្លើយតបទៅនឹងការស្ទង់មតិ transcript នៃការសម្ភាសន៍ និងអក្សរស្រាវជ្រាវពាក់ព័ន្ធនានា ដើម្បីស្វែងយល់ឱ្យបានទូលំទូលាយអំពីស្ថានភាពនៃបរិវត្តកម្មឌីជីថលនៅក្នុងកម្រិតឧត្តមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍។

របាយការណ៍នេះពិនិត្យមើលយ៉ាងលម្អិតទៅលើគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលនៅគ្រឹះស្ថានឧត្តមសិក្សានៅទូទាំងអាស៊ីអាគ្នេយ៍ ព្រមទាំងពិនិត្យពិច័យទៅលើទិដ្ឋភាពផ្សេងៗនៃបរិវត្តកម្មឌីជីថល រួមទាំងការដាក់ឱ្យប្រើប្រាស់នូវថ្នាលសិក្សាឌីជីថល ការប្រើប្រាស់ការវិភាគទិន្នន័យក្នុងការអប់រំ និងការរួមបញ្ចូលបច្ចេកវិទ្យាលេចឡើងថ្មីៗ ដូចជា បញ្ញាសិប្បនិម្មិត (AI) និងបច្ចេកវិទ្យាពិភពនិម្មិត (VR)។ លើសពីនេះ របាយការណ៍នេះក៏សិក្សាអំពីបញ្ហាប្រឈម និងឱកាសដែលមាននៅក្នុងបរិវត្តកម្មឌីជីថលនៅក្នុងតំបន់ ដោយពិចារណាទៅលើកត្តាមួយចំនួន

ដូចជា ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា គោលនយោបាយរដ្ឋាភិបាល និងភាពខុសៗគ្នានៃវប្បធម៌។ ទោះបីជាមានផ្តល់នូវទិដ្ឋភាពគ្រប់ជ្រុងជ្រោយអំពីនិន្នាការ និងបច្ចេកវិទ្យានៃបរិវត្តកម្មឌីជីថល របាយការណ៍នេះមិនបានពិចារណាទៅលើករណីសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សាជាក់លាក់ ឬការអនុវត្តបច្ចេកទេសលម្អិតនោះឡើយ។ ជាចុងក្រោយ របាយការណ៍ផ្តល់នូវការវិភាគយ៉ាងទូលំទូលាយទៅលើនិន្នាការ និងបញ្ហាប្រឈមនានាដែលមានឥទ្ធិពលទៅលើបរិវត្តកម្មឌីជីថលនៅក្នុងឧត្តមសិក្សានៅអាស៊ីអាគ្នេយ៍។

# 3 សាវតារ

## 3.1 សារៈសំខាន់នៃបរិវត្តកម្មឌីជីថលនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា

នៅក្នុងទិដ្ឋភាពឌីជីថលដែលកំពុងមានការវិវឌ្ឍយ៉ាងឆាប់រហ័សនាពេលបច្ចុប្បន្ននេះ សារៈសំខាន់នៃបរិវត្តកម្មឌីជីថលនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា គឺមានច្រើនខ្លាំងនាស់រៀបរាប់មិនអស់ឡើយ។ ក្រៅពីបញ្ហាប្រឈមភ្លាមៗដែលបង្កឡើងដោយជំងឺរាតត្បាត COVID-19 និន្នាការសកល ដូចជា ការកើនឡើងនៃតម្រូវការការងារពីចម្ងាយ សេដ្ឋកិច្ចរយៈពេលខ្លី និងការកើនឡើងនៃតម្រូវការសម្រាប់ការសិក្សាពេញមួយជីវិតបានគូសបញ្ជាក់អំពីតម្រូវការជាបន្ទាន់ ដែលគ្រឹះស្ថានឧត្តមសិក្សាត្រូវដាក់ឱ្យប្រើប្រាស់ឌីជីថលនីយកម្ម (Voinea, 2020)។ និន្នាការទាំងនេះឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរជាមូលដ្ឋានទៅលើវិធីដែលមនុស្សម្នាក់ៗទទួលបានព័ត៌មានប្រើប្រាស់មាតិកា និងទទួលបានជំនាញថ្មីៗ ជាដើម។ អាស្រ័យហេតុនេះ គ្រឹះស្ថានឧត្តមសិក្សាត្រូវតែសម្របវិធីសាស្ត្រក្នុងការបង្រៀន ការសិក្សា និងការសិក្សាស្រាវជ្រាវដើម្បីរក្សាភាពពាក់ព័ន្ធ និងការប្រកួតប្រជែងនៅក្នុងពិភពលោកដែលជំរុញដោយប្រព័ន្ធឌីជីថល។

មូលហេតុចម្បងមួយដែលជាមូលហេតុធ្វើឱ្យបរិវត្តកម្មឌីជីថលមានសារៈសំខាន់សម្រាប់អនាគតនៃការអប់រំនៅថ្នាក់ឧត្តមសិក្សា គឺដោយសារតែបរិវត្តកម្មឌីជីថលអាចពង្រីកលទ្ធភាពទទួលបានការអប់រំរបស់សិស្ស។ បច្ចេកវិទ្យាឌីជីថលមានប្រសិទ្ធភាពដ៏អនុភាពក្នុងការជម្នះឧបសគ្គក្នុងការទទួលបានការអប់រំ ដោយផ្តល់ឱកាសសិក្សាដែលអាចមានភាពបត់បែនបាន និងអាចចូលប្រើប្រាស់បានដល់បុគ្គលម្នាក់ៗមិនថាពួកគេស្ថិតនៅទីតាំងភូមិសាស្ត្រ មានស្ថានភាពសេដ្ឋកិច្ចសង្គម ឬសមត្ថភាពកាយសម្បទាបែបណាក៏ដោយ (Rana, et al. 2020)។ ថ្នាលសិក្សាតាមប្រព័ន្ធអ៊ីនធឺណិត ថ្នាក់រៀនតាមអនឡាញ និងធនធានឌីជីថលអាចឱ្យសិស្សមានលទ្ធភាពបន្តការសិក្សាទៅតាមកម្រិតល្បឿននៃការសិក្សាប្រកបដោយមានភាពងាយស្រួលទៅតាមតម្រូវការរបស់សិស្សម្នាក់ ដោយឈ្នះឧបសគ្គបែបប្រពៃណី ដូចជា ពេលវេលា និងចម្ងាយជាដើម។ ប្រជាធិបតេយ្យភាវូបនីយកម្មនៃការអប់រំបែបនេះមិនត្រឹមតែលើកកម្ពស់បរិយាបន្ន និងភាពចម្រុះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ភាពអង់អាចដល់បុគ្គលម្នាក់ៗឱ្យទទួលបាននូវជំនាញ និងចំណេះដឹងថ្មីៗដើម្បីបន្តបំណងប្រាថ្នាសិក្សាបន្ត និងអភិវឌ្ឍបន្ថែមនូវជំនាញវិជ្ជាជីវៈរបស់ពួកគេទៀតផង។

ជាងនេះទៅទៀត បរិវត្តកម្មឌីជីថលជួយបង្កើនការចូលរួម និងលទ្ធផលសិក្សារបស់សិស្សតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាមានអន្តរកម្មទៅវិញទៅមក និងធនធានពហុប្រព័ន្ធផ្សព្វផ្សាយ។ តាមរយៈការដាក់បញ្ចូលសមាសធាតុ ដូចជា បច្ចេកវិទ្យាពិភពនិម្មិត (VR) និងមាតិកានៅលើពហុប្រព័ន្ធបណ្ដាញដែលមានអន្តរកម្មទៅក្នុងវិធីសាស្ត្របង្រៀនរបស់ពួកគេ អ្នកអប់រំអាចបង្កើតបទពិសោធន៍សិក្សាដ៏ស៊ីជម្រៅ និងថាមវន្ត ដែលអាចទាក់ទាញចំណាប់អារម្មណ៍របស់សិស្ស និងជំរុញដល់ការចង់ចេះចង់ដឹងរបស់ពួកគេ (Sharma, et al. 2024)។ វិធីសាស្ត្រគរុកោសល្យប្រកបដោយនវានុវត្តន៍ទាំងនេះមិនត្រឹមតែលើកកម្ពស់ការសិក្សាសកម្ម និងការត្រិះរិះពិចារណាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយសម្រួលដល់ការយល់ដឹងកាន់តែស៊ីជម្រៅ និងការរក្សាឯកសារនៃវគ្គសិក្សា ដែលនៅចុងក្រោយ នាំឱ្យមានលទ្ធផលអប់រំកាន់តែកែលម្អថែមទៀតផង។

លើសពីនេះទៅទៀត ការបរិវត្តកម្មឌីជីថលដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំសិស្សឱ្យទទួលបានជោគជ័យនៅក្នុងសេដ្ឋកិច្ចដែលជំរុញដោយឌីជីថល។ នៅពេលដែលមានការអភិវឌ្ឍបដិវត្តន៍ឧស្សាហកម្មទី 4 ដែលកំណត់លក្ខណៈចរិតដោយការដាក់បញ្ចូលគ្នានៃបច្ចេកវិទ្យាឌីជីថល រូបវន្ត និងជីវសាស្ត្រ តម្រូវការអក្ខរកម្មឌីជីថល ជំនាញបច្ចេកទេស និងការសម្របខ្លួនគឺមានការកើនឡើងកាន់តែខ្ពស់មិនធ្លាប់មានពីមុនមក។ គ្រឹះស្ថានឧត្តមសិក្សាមានទំនួលខុសត្រូវក្នុងការបំពាក់បំប៉នឱ្យសិស្សនូវចំណេះដឹង ជំនាញ និងផ្នត់គំនិត ដែលត្រូវការជាចាំបាច់ដើម្បីជំរុញការរីកចម្រើននៅក្នុងទិដ្ឋភាពដែលមានកំពុងមានការផ្លាស់ប្ដូរយ៉ាងឆាប់រហ័សនេះ។ តាមរយៈការរួមបញ្ចូលបច្ចេកវិទ្យាឌីជីថលនៅក្នុងកម្មវិធីសិក្សា និងការផ្ដល់នូវបទពិសោធន៍អនុវត្តផ្ទាល់ជាមួយបច្ចេកវិទ្យាដែលកំពុងមានការរីកចម្រើន គ្រឹះស្ថានឧត្តមសិក្សានានាអាចរៀបចំសិស្សឱ្យក្លាយជាធនធានដែលអាចដោះស្រាយបញ្ហាបានឆាប់រហ័ស អ្នកគិតដោយភាពច្នៃប្រឌិត និងអ្នកសិក្សាពេញមួយជីវិត ដែលបានបំពាក់បំប៉នយ៉ាងល្អប្រសើរនៅក្នុងការស្វែងយល់ពីភាពស្មុគស្មាញនៃយុគសម័យឌីជីថលនេះ។

សរុបមក បរិវត្តកម្មឌីជីថលគឺមិនមែនគ្រាន់តែមានភាពចាំបាច់ផ្នែកបច្ចេកវិទ្យាប៉ុណ្ណោះទេ ប៉ុន្តែក៏មានភាពចាំបាច់ជាយុទ្ធសាស្ត្រសម្រាប់អនាគតនៃការអប់រំនៅថ្នាក់ឧត្តមសិក្សាផងដែរ។ តាមរយៈការធ្វើឌីជីថលនីយកម្ម គ្រឹះស្ថានឧត្តមសិក្សានានាអាចសម្រេចបាននូវសក្ដានុពលឱកាសថ្មីសម្រាប់នវានុវត្តន៍ កិច្ចសហការ និងភាពជោគជ័យរបស់សិស្ស ខណៈពេលដែលអាចផ្ដល់ជាដំណោះស្រាយចំពោះតម្រូវការ និងការរំពឹងទុករបស់អ្នកសិក្សា និងសង្គមជាតិទាំងមូលតែម្ដង។

## 3.2 ស្ថានភាពបច្ចុប្បន្ននៃបរិវត្តកម្មឌីជីថលនៅអាស៊ីអាគ្នេយ៍

**ស្ថានភាពបច្ចុប្បន្ននៃបរិវត្តកម្មឌីជីថលក្នុងការអប់រំនៅថ្នាក់ឧត្តមសិក្សានៅទូទាំងតំបន់អាស៊ីអាគ្នេយ៍គឺឆ្លុះបញ្ចាំងអំពីទិដ្ឋភាពចម្រុះដែលមានឥទ្ធិពលដោយកម្រិតផ្សេងៗគ្នានៃហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា សមត្ថភាពរបស់គ្រឹះស្ថានឧត្តមសិក្សា និងការគាំទ្រពីសំណាក់រដ្ឋាភិបាល។ នៅក្នុងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចអភិវឌ្ឍន៍ ដូចជា សិង្ហបុរី ម៉ាឡេស៊ី និងថៃ គ្រឹះស្ថានឧត្តមសិក្សាបានបោះជំហានគួរឱ្យកត់សម្គាល់ក្នុងការទទួលយកបច្ចេកវិទ្យាឌីជីថល ហើយបានដាក់បញ្ចូលបច្ចេកវិទ្យាឌីជីថលនៅក្នុងការអនុវត្តការបង្រៀន ការសិក្សា និងការសិក្សាស្រាវជ្រាវរបស់ខ្លួន។ គ្រឹះស្ថានឧត្តមសិក្សាទាំងនេះទទួលបានផលប្រយោជន៍ពីហេដ្ឋារចនាសម្ព័ន្ធឌីជីថលដ៏រឹងមាំ ការវិនិយោគរបស់រដ្ឋាភិបាលទៅលើការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍ និងវប្បធម៌នៃនវានុវត្តន៍ និងសហគ្រិនភាព។**

ផ្ទុយទៅវិញ នៅក្នុងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចមិនសូវមានការអភិវឌ្ឍ ដូចជា កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា គ្រឹះស្ថានឧត្តមសិក្សាប្រឈមមុខនឹងបញ្ហាប្រឈមកាន់តែខ្លាំងឡើងក្នុងការទទួលយកបរិវត្តកម្មឌីជីថល ដោយសារតែកត្តាមួយចំនួន ដូចជា ធនធានមានកម្រិត ឧបសគ្គផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងភាពរុញរារបស់គ្រឹះស្ថានឧត្តមសិក្សាខ្លួនឯង។ ទោះជាយ៉ាងណាក៏ដោយ ជំងឺរាតត្បាតកូវីដ-19 បានក្លាយជាកាតាលីករនាំឱ្យមានការផ្លាស់ប្តូរ ដោយបានជំរុញការបង្កើនល្បឿនក្នុងការការទទួលយកបច្ចេកវិទ្យាឌីជីថល និងថ្នាលសិក្សាតាមប្រព័ន្ធអ៊ីនធឺណិតនៅទូទាំងតំបន់នេះ។ គ្រឹះស្ថានឧត្តមសិក្សាដែលធ្លាប់តែមានភាពស្ទាក់ស្ទើរក្នុងការទទួលយកបរិវត្តកម្មឌីជីថលត្រូវបង្ខំចិត្តសម្របខ្លួនយ៉ាងឆាប់រហ័សដើម្បីធានាឱ្យបាននូវការបន្តការអប់រំនៅពេលដែលប្រឈមមុខនឹងការរំខានដល់ការអប់រំដែលមិនធ្លាប់មានពីមុនមក។

ទោះបីជាសម្រេចបាននូវវឌ្ឍនភាពក៏ដោយ ក៏នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើដើម្បីសម្រេចឱ្យបានបរិវត្តកម្មឌីជីថលយ៉ាងទូលំទូលាយនៅក្នុងការអប់រំនៅថ្នាក់ឧត្តមសិក្សានៅទូទាំងអាស៊ីអាគ្នេយ៍ទាំងមូល។ គ្រឹះស្ថានត្រូវតែដោះស្រាយបញ្ហានានា ដូចជា អក្ខរកម្មឌីជីថល លទ្ធភាពទទួលបានការអប់រំ និងលទ្ធភាពគ្រប់គ្រាន់ក្នុងធ្វើយ៉ាងនាធានាថាសិស្សទាំងអស់មានលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌។ ជាងនេះទៅទៀត កិច្ចសហការរវាងរដ្ឋាភិបាល ដៃគូឧស្សាហកម្ម និងស្ថាប័នអប់រំគឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការជំរុញនវានុវត្តន៍ ការដោះស្រាយគម្លាតហេដ្ឋារចនាសម្ព័ន្ធ និងការកសាងសមត្ថភាពឌីជីថលនៅក្នុងកម្រិតវិសាលភាពទូលំទូលាយ (Aung, & Aye, 2024)។

## 3.3 ក្របខណ្ឌសម្រាប់បរិវត្តកម្មឌីជីថលនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា៖

ដើម្បីផ្តល់ជាការណែនាំ និងវាយតម្លៃទៅលើកិច្ចខិតខំប្រឹងប្រែងបរិវត្តកម្មឌីជីថលនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា គ្រឹះស្ថានឧត្តមសិក្សាអាចប្រើប្រាស់ក្របខណ្ឌទ្រឹស្តី ឬម៉ូដែលផ្សេងៗ

ដែលផ្តល់ជាវិធីសាស្ត្ររចនាសម្ព័ន្ធសម្រាប់ការធ្វើផែនការ ការអនុវត្ត និងការវាយតម្លៃគំនិតផ្តួចផ្តើមឌីជីថល។ ក្របខណ្ឌមួយក្នុងចំណោមនោះគឺ ម៉ូដែល ADKAR ដែលផ្តោតលើដំណើរការផ្លាស់ប្តូរនីមួយៗដោយដោះស្រាយបញ្ហានៃការយល់ដឹង បំណងប្រាថ្នា ចំណេះដឹង សមត្ថភាព និងការពង្រឹងបន្ថែម។ តាមរយៈការស្វែងយល់ និងការដោះស្រាយទិដ្ឋភាពធនធានមនុស្សនៃការផ្លាស់ប្តូរ គ្រឹះស្ថានឧត្តមសិក្សាអាចជួយសម្រួលដល់គំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលដោយជោគជ័យ និងជម្នះបញ្ហារុញរាចំពោះការផ្លាស់ប្តូរ (Inui, 2020)។

ក្របខណ្ឌមួយផ្សេងទៀតដែលគ្រឹះស្ថានឧត្តមសិក្សាអាចពិចារណាគឺ ក្របខណ្ឌ McKinsey 7S ដែលវាយតម្លៃទៅលើសមាសធាតុសំខាន់ៗចំនួនប្រាំពីរ រួមមាន យុទ្ធសាស្ត្រ រចនាសម្ព័ន្ធ ប្រព័ន្ធ បុគ្គលិក ជំនាញ រចនាបថ (style) និងគុណតម្លៃរួម ដើម្បីវាយតម្លៃការត្រៀមលក្ខណៈ និងប្រសិទ្ធភាពនៃគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថល។ តាមរយៈការពិនិត្យមើលទៅលើកត្តាដែលទាក់ទងគ្នាទៅវិញទៅមកទាំងនេះ គ្រឹះស្ថានឧត្តមសិក្សាអាចកំណត់ផ្នែកដែលត្រូវធ្វើការកែលម្អ និងបង្កើតវិធីសាស្ត្រគ្រប់ជ្រុងជ្រោយចំពោះបរិវត្តកម្មឌីជីថល ដែលស្របតាមគោលបំណងយុទ្ធសាស្ត្រ និងវប្បធម៌របស់គ្រឹះស្ថានឧត្តមសិក្សា។

លើសពីនេះ ម៉ូដែល SAMR (ការជំនួស (Substitution) ការកែលម្អ (Augmentation) ការកែសម្រួល (Modification) ការកំណត់ឡើងវិញ (Redefinition)) ផ្តល់ជាក្របខណ្ឌសម្រាប់ការវាយតម្លៃទៅលើការរួមបញ្ចូលបច្ចេកវិទ្យានៅក្នុងការអនុវត្តការបង្រៀន និងការសិក្សា។ តាមរយៈបរិវត្តកម្មឌីជីថលឱ្យលើសពីការគ្រាន់តែជំនួសវិធីសាស្ត្របង្រៀនបែបបុរាណជាមួយនឹងការប្រើប្រាស់ឧបករណ៍ឌីជីថលដើម្បីកំណត់ឡើងវិញនូវបទពិសោធន៍សិក្សា ដោយការធ្វើបរិវត្តកម្មបច្ចេកវិទ្យា គ្រឹះស្ថានអប់រំអាចបង្កើនផលជះនៃបរិវត្តកម្មឌីជីថលទៅលើលទ្ធផលនៃការអប់រំក្នុងកម្រិតអតិបរមា។

សរុបមក តាមរយៈការអនុវត្តក្របខណ្ឌទ្រឹស្តី ឬម៉ូដែលផ្សេងៗ គ្រឹះស្ថានឧត្តមសិក្សានៅអាស៊ីអាគ្នេយ៍អាច អនុវត្តភាពស្មុគស្មាញនៃបរិវត្តកម្មឌីជីថលកាន់តែមានប្រសិទ្ធភាព ហើយធានាថាកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេស្របតាមគោលដៅ អាទិភាព និងតម្រូវការរបស់អ្នកពាក់ព័ន្ធ។ ការពិភាក្សាអំពីការជ្រើសរើសម៉ូដែលណាដែលត្រូវប្រើប្រាស់សម្រាប់ផ្តល់ការណែនាំ និងការវាយតម្លៃកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើបរិវត្តកម្មឌីជីថលនៅគ្រឹះស្ថានឧត្តមសិក្សា គឺអាស្រ័យទៅលើកត្តាផ្សេងៗ រួមទាំង គោលដៅ វប្បធម៌ និងតម្រូវការជាក់លាក់របស់គ្រឹះស្ថានឧត្តមសិក្សា។ សូមពិនិត្យមើលដោយសង្ខេបទៅលើម៉ូដែលទាំងបីដែលបានរៀបរាប់ខាងលើដូចតទៅ៖ ម៉ូដែល ADKAR ក្របខណ្ឌ McKinsey 7S និង SAMR៖

- ម៉ូដែល ADKAR (Boca, 2013)៖ ម៉ូដែលនេះផ្តោតទៅលើដំណើរការនៃការផ្លាស់ប្តូរ បុគ្គលម្នាក់ៗ ការដោះស្រាយការយល់ដឹង បំណងប្រាថ្នា ចំណេះដឹង សមត្ថភាព និងការពង្រឹងបន្ថែម។ ម៉ូដែលនេះមានប្រយោជន៍ជាពិសេសសម្រាប់ការស្វែងយល់ និងការគ្រប់គ្រងទិដ្ឋភាពផ្លាស់ប្តូរធនធានមនុស្ស ដែលតែងតែមានសារៈសំខាន់នៅក្នុងគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលប្រកបដោយជោគជ័យ។ តាមរយៈការសង្កត់ធ្ងន់ទៅលើសមាសធាតុ

ដូចជា ការកសាងការយល់ដឹង ការជំរុញឱ្យមានបំណងប្រាថ្នាផ្លាស់ប្តូរ ការផ្តល់ចំណេះដឹង និងជំនាញចាំបាច់ ការផ្តល់លទ្ធភាព និងការពង្រឹងការផ្លាស់ប្តូរ គ្រឹះស្ថានឧត្តមសិក្សាអាចគ្រប់គ្រងការរុញរាដោយប្រសិទ្ធភាព និងធានាឱ្យមានធ្វើអន្តរកាលកាន់តែរលូន។

- ក្របខណ្ឌ McKinsey 7S (Singh, 2013)៖ ក្របខណ្ឌនេះវាយតម្លៃទៅលើសមាសធាតុសំខាន់ៗចំនួនប្រាំពីរ រួមមាន យុទ្ធសាស្ត្រ រចនាសម្ព័ន្ធ ប្រព័ន្ធ បុគ្គលិក ជំនាញ រចនាបថ (style) និងគុណតម្លៃរួម ដើម្បីវាយតម្លៃការត្រៀមលក្ខណៈ និងប្រសិទ្ធភាពនៃគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថល។ ម៉ូដែលនេះផ្តល់នូវវិធីសាស្ត្រដ៏ទូលំទូលាយដោយពិនិត្យមើលទាំងទៅលើទិដ្ឋភាពស្ថាប័ន និងវប្បធម៌។ តាមរយៈការវិភាគកត្តាដែលទាក់ទងគ្នាទាំងនេះ គ្រឹះស្ថានឧត្តមសិក្សាអាចកំណត់ផ្នែកដែលត្រូវផ្តល់ការយកចិត្តទុកដាក់ និងការបន្ស៊ីគ្នាដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនៃបរិវត្តកម្មឌីជីថលប្រកបដោយជោគជ័យ។ ម៉ូដែលនេះមានប្រយោជន៍ជាពិសេសក្នុងការធានាថា គំនិតផ្តួចផ្តើមឌីជីថលត្រូវបានដាក់បញ្ចូលដោយរលូនទៅក្នុងយុទ្ធសាស្ត្រ និងវប្បធម៌រួមរបស់គ្រឹះស្ថានឧត្តមសិក្សា។
- ម៉ូដែល SAMR (Romrell, et al., 2014)៖ ខុសពីម៉ូដែលពីរខាងលើ ម៉ូដែល SAMR ផ្តោតជាពិសេសទៅលើការវាយតម្លៃការរួមបញ្ចូលបច្ចេកវិទ្យានៅក្នុងការអនុវត្តការបង្រៀន និងការសិក្សា។ ម៉ូដែលនេះចាត់ថ្នាក់ការរួមបញ្ចូលបច្ចេកវិទ្យាទៅជាបួនកម្រិត៖ (ការជំនួស (Substitution) ការកែលម្អ (Augmentation) ការកែសម្រួល (Modification) ការកំណត់ឡើងវិញ (Redefinition)។ ម៉ូដែលនេះលើកទឹកចិត្តឱ្យអ្នកអប់រំឱ្យអនុវត្តលើសពីការគ្រាន់តែប្រើប្រាស់បច្ចេកវិទ្យាជំនួសឱ្យវិធីសាស្ត្របែបប្រពៃណីដើម្បីកំណត់ឡើងវិញ និងផ្លាស់ប្តូរបទពិសោធន៍សិក្សា។ ម៉ូដែលនេះមានទំនាក់ទំនងជាពិសេសចំពោះគ្រឹះស្ថានឧត្តមសិក្សាដែលមានបំណងបង្កើនផលជះជាអតិបរមានៃបច្ចេកវិទ្យាទៅលើលទ្ធផលអប់រំ និងនវានុវត្តន៍ក្នុងការអនុវត្តការបង្រៀនរបស់ពួកគេ។

នៅពេលធ្វើការសម្រេចចិត្តថាតើត្រូវប្រើប្រាស់ម៉ូដែលណា គ្រឹះស្ថានឧត្តមសិក្សាគួរតែពិចារណាទៅលើបរិបទជាក់លាក់ គោលបំណង និងដំណាក់កាលនៃដំណើរធ្វើបរិវត្តកម្មឌីជីថលរបស់ខ្លួន (Hashim & Leitner, 2014)។ ឧទាហរណ៍ ប្រសិនបើការផ្តោតចម្បងទៅលើការដោះស្រាយការរុញរាទៅចំពោះការផ្លាស់ប្តូរ និងការគ្រប់គ្រងការធ្វើអន្តរកាលរបស់បុគ្គលម្នាក់ៗ នោះម៉ូដែល ADKAR អាចជាជម្រើសដ៏សមស្របបំផុត។ ប្រសិនបើគ្រឹះស្ថានឧត្តមសិក្សាចង់ធ្វើការវាយតម្លៃការត្រៀមលក្ខណៈជារួម និងការបន្ស៊ីសម្រាប់ការធ្វើបរិវត្តកម្មឌីជីថល នោះក្របខណ្ឌ McKinsey 7S អាចជាជម្រើសដ៏សមស្របជាង។ ទន្ទឹមនឹងនេះដែរ ប្រសិនបើក្តីកង្វល់ចម្បងគឺការបង្កើនប្រសិទ្ធភាពនៃការរួមបញ្ចូលបច្ចេកវិទ្យានៅក្នុងការបង្រៀន និងការសិក្សា នោះម៉ូដែល SAMR គឺជាជម្រើសដ៏មានតម្លៃសម្រាប់បញ្ហានេះ។ នៅចុងក្រោយ ការផ្សំបញ្ចូលគ្នានៃម៉ូដែលទាំងនេះ ឬការសម្របម៉ូដែលទាំងនេះដើម្បីបំពេញតាមតម្រូវការពិសេសរបស់គ្រឹះស្ថានឧត្តមសិក្សា ក៏អាចជាវិធីសាស្ត្រគ្រប់ជ្រុងជ្រោយបំផុតដែរ។

# 4 បរិវត្តកម្មឌីជីថលនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា៖ និន្នាការ និងបច្ចេកវិទ្យាសំខាន់ៗ តំបន់

## 4.1 និន្នាការ និងបច្ចេកវិទ្យាសំខាន់ៗ៖

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ថ្នាលសិក្សាអនឡាញបានក្លាយជាឧបករណ៍ដែលមិនអាចខ្វះបានសម្រាប់គ្រឹះស្ថានឧត្តមសិក្សា ដោយផ្តល់ជាមធ្យោបាយដ៏សម្បូរបែប និងអាចប្រើប្រាស់ក្នុងការការផ្តល់មាតិកាអប់រំដល់សិស្ស។ ថ្នាល ដូចជា Moodle, Canvas, និង Blackboard ចាប់ផ្តើមមានការទទួលយកយ៉ាងទូលំទូលាយនៅក្នុងចំណោមអ្នកអប់រំ និងអ្នកសិក្សា ដោយផ្តល់នូវមជ្ឈមណ្ឌលកណ្តាលសម្រាប់ឯកសារវគ្គសិក្សា កិច្ចការ ការពិភាក្សា និងការវាយតម្លៃ។ ថ្នាលទាំងនេះអាចឱ្យសិស្សចូលប្រើប្រាស់ធនធានអប់រំពីចម្ងាយ ប្រើប្រាស់មាតិកានៃវគ្គសិក្សាទៅតាមកម្រិតល្បឿនសិក្សាផ្ទាល់របស់ពួកគេ និងសហការជាមួយមិត្តភក្តិ និងគ្រូបង្ហាត់នៅលើអនឡាញ។

## 4.2 បញ្ហាប្រឈម និងឱកាសក្នុងកម្រិតតំបន់៖

ទោះបីជាបរិវត្តកម្មឌីជីថលមានសក្តានុពលយ៉ាងធំធេងសម្រាប់ការអប់រំថ្នាក់ឧត្តមសិក្សានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក៏ដោយ ក៏គ្រឹះស្ថានអប់រំប្រឈមនឹងបញ្ហាប្រឈមទូទៅមួយចំនួនដែលចាំបាច់ត្រូវតែដោះស្រាយដើម្បីសម្រេចបាននូវសក្តានុពលពេញលេញនេះ។ បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមធំបំផុត គឺលទ្ធភាពមានកម្រិតក្នុងការតភ្ជាប់អ៊ីនធឺណិតដែលមានស្ថិរភាព និងហេដ្ឋារចនាសម្ព័ន្ធឌីជីថលមិនគ្រប់គ្រាន់ ជាពិសេស នៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាល ដែលបញ្ហានៃការតភ្ជាប់អ៊ីនធឺណិតគឺមានកាន់តែខ្លាំង។ ដើម្បីជម្នះបញ្ហាប្រឈមនេះ គ្រឹះស្ថានឧត្តមសិក្សានានាត្រូវតែវិនិយោគទៅលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងពង្រីកលទ្ធភាពតភ្ជាប់អ៊ីនធឺណិតល្បឿនលឿននៅទូទាំងតំបន់ទាំងមូល។

លើសពីនេះ អក្ខរកម្មឌីជីថលនៅតែជាបញ្ហាប្រឈមដ៏ធំធេង ដោយនិស្សិត និងសាស្ត្រាចារ្យជាច្រើននៅខ្វះជំនាញត្រូវការជាចាំបាច់ក្នុងការប្រើប្រាស់ និងទាញប្រយោជន៍ឱ្យបានពេញលេញពីបច្ចេកវិទ្យាឌីជីថល។ ការដោះស្រាយបញ្ហាគម្លាតជំនាញឌីជីថលតាមរយៈកម្មវិធីបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈគឺជាកត្តាដ៏ចាំបាច់ដើម្បីធានាថាភាគីពាក់ព័ន្ធទាំងអស់អាចស្រាវជ្រាវ និងប្រើប្រាស់ឧបករណ៍ឌីជីថលក្នុងគោលបំណងបង្រៀន សិក្សា និងស្រាវជ្រាវឱ្យមានប្រសិទ្ធភាព។

លើសពីនេះ ថ្លៃចំណាយនៃការអនុវត្ត និងតំហែទាំបច្ចេកវិទ្យាឌីជីថលអាចមានតម្លៃខ្ពស់ជ្រុលសម្រាប់គ្រឹះស្ថានឧត្តមសិក្សាមួយចំនួន ជាពិសេស សាកលវិទ្យាល័យតូចៗ និងសាកលវិទ្យាល័យដែលមិនសូវមានថវិកាគាំទ្រច្រើន។

ការស្វែងរកដំណោះស្រាយដែលមានប្រសិទ្ធភាពថ្លៃចំណាយ និងការធានានូវការផ្តល់មូលនិធិសម្រាប់គំនិតផ្តួចផ្តើមឌីជីថល គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ដើម្បីធ្វើយ៉ាងណាធានាឱ្យបាននូវលទ្ធភាពទទួលបានធនធានឌីជីថល និងឱកាសប្រកបដោយសមធម៌សម្រាប់សិស្សទាំងអស់។

ជាងនេះទៅទៀត ការក្តីបារម្ភចំពោះភាពឯកជន និងសន្តិសុខទិន្នន័យកាន់តែមានការលើកឡើងច្រើនឡើងយ៉ាងលេចធ្លោដោយសារតែគ្រឹះស្ថានអប់រំប្រមូល និងវិភាគទិន្នន័យយ៉ាងច្រើនរបស់សិស្សនិស្សិតដែលមានលក្ខណៈរសើប។ ការការពារឯកជនភាពរបស់សិស្ស និងការធានានូវអនុលោមតាមបទប្បញ្ញត្តិស្តីពីការការពារទិន្នន័យ គឺជាកត្តាដ៏សំខាន់បំផុតក្នុងការរក្សាការជឿជាក់ និងទំនុកចិត្តមកលើប្រព័ន្ធឌីជីថល។

ទោះបីជាការអប់រំថ្នាក់ឧត្តមសិក្សានៅអាស៊ីអាគ្នេយ៍ប្រឈមនឹងបញ្ហាប្រឈមទាំងនេះក៏ដោយក៏នៅមានឱកាសសំខាន់ៗជាច្រើនសម្រាប់ការរីកចម្រើន និងការធ្វើឱ្យប្រសើរឡើងក្នុងធ្វើការបរិវត្តកម្មឌីជីថលដែរនៅក្នុងតំបន់នេះ។ កិច្ចសហការ និងភាពជាដៃគូជាមួយដៃគូឧស្សាហកម្ម ស្ថាប័នរដ្ឋាភិបាល និងគ្រឹះស្ថានអប់រំផ្សេងទៀតអាចជួយសម្រួលដល់ការចែករំលែកចំណេះដឹង ការប្រមូលផ្តុំធនធាន និងនវានុវត្តន៍នៅក្នុងគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថល។ ជាងនេះទៅទៀត ការទទួលយកនូវវប្បធម៌នវានុវត្តន៍ និងការដកពិសោធន៍ អាចឱ្យគ្រឹះស្ថានអប់រំនានាស្វែងរកបច្ចេកវិទ្យា វិធីសាស្ត្រគរុកោសល្យ និងគំរូការងារ (គំរូអាជីវកម្ម) ថ្មីៗដើម្បីជំរុញដល់ការកែលម្អជាបន្ត ព្រមទាំងលើកកម្ពស់វប្បធម៌នៃការសិក្សាពេញមួយជីវិត និងនវានុវត្តន៍ថែមទៀតផង។

សរុបមក បរិវត្តកម្មឌីជីថលមានទាំងពីបញ្ហាប្រឈម និងឱកាសសម្រាប់គ្រឹះស្ថានឧត្តមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍។ តាមរយៈការដោះស្រាយបញ្ហាប្រឈមរួមទាំងនេះ ការក្រសោបយកឱកាសដើម្បីការរីកចម្រើន និងការកែលម្អ ក៏ដូចជាការទទួលយកបច្ចេកវិទ្យាឌីជីថលដើម្បីបង្កើនប្រសិទ្ធភាពនៃការបង្រៀន ការសិក្សា និងដំណើរការរដ្ឋបាល គ្រឹះស្ថានឧត្តមសិក្សានឹងអាចឈានមុខផ្នែកនវានុវត្តន៍ការអប់រំ និងរួមចំណែកដល់ការរីកចម្រើនការអប់រំថ្នាក់ឧត្តមសិក្សានៅក្នុងតំបន់។

# 5 ទស្សនៈជាក់លាក់នៅកម្រិតប្រទេស

## 5.1 ទិដ្ឋភាពនៃបច្ចុប្បន្នការអប់រំថ្នាក់ឧត្តមសិក្សា

នៅទីក្រុងគូឡាឡាំពួ ប្រតិភូតំណាងមកពីប្រទេសឡាវ កម្ពុជា និងម៉ាឡេស៊ីបានផ្តល់ការវិភាគស៊ីជម្រៅអំពីស្ថានភាពបច្ចុប្បន្ននៃការអប់រំថ្នាក់ឧត្តមសិក្សានៅក្នុងប្រទេសរៀងៗខ្លួន។ ការធ្វើបទបង្ហាញរបស់ប្រទេសនីមួយៗបានឆ្លុះបញ្ចាំងអំពីកត្តាចម្រុះដែលបង្កើតទិដ្ឋភាពនៃការអប់រំថ្នាក់ឧត្តមសិក្សា រួមទាំង ហេដ្ឋារចនាសម្ព័ន្ធ អត្រាចុះឈ្មោះចូលរៀន ក្របខណ្ឌអភិបាលកិច្ច និងយន្តការធានាគុណភាព (Sa-ngiamwibool, & Wisaeng, 2022)។

ប្រទេសម៉ាឡេស៊ី ដែលស្ថិតឈានមុខផ្នែកអភិវឌ្ឍការអប់រំថ្នាក់ឧត្តមសិក្សានៅក្នុងតំបន់ បានបង្ហាញអំពីប្រព័ន្ធដែលបានបង្កើតឡើងយ៉ាងល្អប្រសើរ ដែលអាចចាត់ទុកថាជាប្រទេសដែលមានហេដ្ឋារចនាសម្ព័ន្ធទំនើប អត្រាចុះឈ្មោះចូលរៀនខ្ពស់ និងវិធានការធានាគុណភាពយ៉ាងតឹងរ៉ឹង។ ប្រទេសនេះបានវិនិយោគជាយុទ្ធសាស្ត្រទៅលើការកសាងសាកលវិទ្យាល័យ និងគ្រឹះស្ថានស្រាវជ្រាវលំដាប់ថ្នាក់ពិភពលោក ដោយបានទាក់ទាញក្រុមសិស្សនិស្សិត និងបញ្ញវន្តជាច្រើនមកពីជុំវិញពិភពលោក។
ប្រទេសម៉ាឡេស៊ីសង្កត់ធ្ងន់ទៅលើការធានាគុណភាព ហើយការទទួលស្គាល់គុណភាពបានធ្វើឱ្យប្រទេសនេះមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងនាមជាប្រទេសទិសដៅឈានមុខគេផ្នែកការអប់រំថ្នាក់ឧត្តមសិក្សានៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

ផ្ទុយទៅវិញ ប្រទេសកម្ពុជា និងឡាវប្រឈមមុខនឹងបញ្ហាប្រឈមគួរឱ្យកត់សម្គាល់នៅក្នុងវិស័យអប់រំថ្នាក់ឧត្តមសិក្សានៅក្នុងប្រទេស ដោយសារតែកត្តាធនធានមានកម្រិត ឱនភាពហេដ្ឋារចនាសម្ព័ន្ធ និងបញ្ហាអភិបាលកិច្ច (Chaphichith, 2014) (Sen, 2013)។ ទោះបីជាមានខិតខំប្រឹងប្រែងដើម្បីពង្រីកលទ្ធភាពទទួលបានការអប់រំ និងការលើកកម្ពស់គុណភាពរបស់ស្ថាប័នក៏ដោយ ប្រទេសទាំងពីរនេះនៅតែបន្តជួបបញ្ហាជាច្រើន ដូចជាអត្រាចុះឈ្មោះចូលរៀនទាបអគារសិក្សាមិនគ្រប់គ្រាន់ និងលទ្ធផលអប់រំមានកម្រិតខុសៗគ្នា (Madhur, 2014) (Un, & Sok, 2018)។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជា និងឡាវមានភាពធន់ និងបានប្ដេជ្ញាចិត្តដោះស្រាយបញ្ហាប្រឈមទាំងនេះ ដោយបានគូសបញ្ជាក់អំពីផែនការដ៏មហិច្ឆិតារបស់ខ្លួននៅក្នុង អភិវឌ្ឍប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សាឱ្យមានការរីកចម្រើន។

## 5.2 គំនិតផ្តួចផ្តើម និងវឌ្ឍនភាពនៃបរិវត្តកម្មឌីជីថល៖

តំណាងមកពីប្រទេសឡាវ កម្ពុជា និងម៉ាឡេស៊ីបានបង្ហាញអំពីគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលផ្សេងៗ ដែលមានគោលដៅធ្វើបដិវត្តការបង្រៀន ការសិក្សា និងដំណើរការរដ្ឋបាលនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា។

នៅក្នុងប្រទេសម៉ាឡេស៊ី គំនិតផ្តួចផ្តើមគួរឱ្យកត់សម្គាល់ រួមមានដូចជា ការអនុវត្តថ្នាលសិក្សាឌីជីថលគ្រប់ជ្រុងជ្រោយ និងគម្រោងអភិវឌ្ឍន៍វគ្គសិក្សាតាមប្រព័ន្ធអ៊ីនធឺណិត។ គំនិតផ្តួចផ្តើមទាំងនេះប្រើប្រាស់បច្ចេកវិទ្យាទំនើបចុងក្រោយដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំ និងលើកកម្ពស់បរិយាកាសសិក្សាបែបអន្តរកម្ម ដែលបំពេញតាមតម្រូវការ និងចំណូលចិត្តរបស់សិស្សផ្សេងៗគ្នា។ លើសពីនេះទៅទៀត ប្រទេសម៉ាឡេស៊ីបានបោះជំហានគួរឱ្យកត់សម្គាល់ក្នុងការប្រើប្រាស់បច្ចេកវិទ្យា blockchain ដើម្បីដំណើរការបញ្ជាក់អត្តសញ្ញាណ និងវិញ្ញាបនបត្រ ដោយធ្វើយ៉ាងធានាឱ្យបាននូវសុចរិតភាព និងភាពងាយស្រួលយកតាមខ្លួននូវលិខិតបញ្ជាក់កម្រិតសិក្សានៅក្នុងយុគសម័យឌីជីថល។

នៅប្រទេសកម្ពុជា និងឡាវ ទោះបីជាកំពុងប្រឈមនឹងបញ្ហាប្រឈមផ្នែកហេដ្ឋារចនាសម្ព័ន្ធយ៉ាងណាក៏ដោយ ក៏នៅក្នុងប្រទេសទាំងពីរនេះ កំពុងខិតខំប្រឹងប្រែងដាក់បញ្ចូលបច្ចេកវិទ្យាឌីជីថលទៅក្នុងប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សា។ គំនិតផ្តួចផ្តើមទាំងនេះ រួមមានដូចជា ឧបករណ៍វិភាគដំណើរការដោយ AI និងថ្នាក់រៀនតាមអនឡាញ ដែលមានគោលបំណងលើកកម្ពស់ការអនុវត្តគរុកោសល្យ និងពង្រីកឱកាសអប់រំ ជាពិសេស នៅតាមតំបន់ដាច់ស្រយាល ដែលអាចមានលទ្ធភាពទទួលបានធនធានអប់រំតាមបែបប្រពៃណីមានកម្រិត។ ទោះបីជាកិច្ចការនេះអាចមានវឌ្ឍនភាពបន្តិចម្តងៗ ប្រទេសទាំងពីរនេះបានប្តេជ្ញាចិត្តទាញយកសក្តានុពលនៃបច្ចេកវិទ្យាដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងវិស័យអប់រំថ្នាក់ឧត្តមសិក្សានៅក្នុងប្រទេសរៀងៗខ្លួន។

## 5.3 បញ្ហាប្រឈម និងឱកាស

ទោះបីជាប្រទេសនីមួយៗប្រឈមមុខនឹងបញ្ហាប្រឈមខុសប្លែកតាមកម្រិតផ្សេងៗក្នុងដំណើរនៃការធ្វើបរិវត្តកម្មឌីជីថលក៏ដោយ ក៏ប្រទេសទាំងនេះមានឱកាសគួរឱ្យកត់សម្គាល់សម្រាប់កំណើន និងនវានុវត្តន៍ដែរ។ ប្រទេសកម្ពុជា និងឡាវប្រឈមមុខនឹងឧបសគ្គមួយចំនួន ដូចជា ហេដ្ឋារចនាសម្ព័ន្ធនៅមានកម្រិត កង្វះថវិកា និងកង្វះបុគ្គលិកជំនាញ ជាពិសេស នៅតាមសាកលវិទ្យាល័យនៅតាមខេត្តឆ្ងាយពីរាជធានី ដែលជាឧបសគ្គក្នុងការអនុវត្តគំនិតផ្តួចផ្តើមឌីជីថលឱ្យមានប្រសិទ្ធភាព។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមទាំងនេះក៏នាំមកជាមួយនូវឱកាសសម្រាប់កិច្ចសហការ និងការចែករំលែកចំណេះដឹង ក៏ដូចជា សក្តានុពលក្នុងការហក់លោតឱ្យផុតពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបប្រពៃណី និងក្រសោបយកនូវការអនុវត្តបច្ចេកវិទ្យាទំនើបចុងក្រោយដើម្បីជំរុញឱ្យមានការរីកចំរើនយ៉ាងឆាប់រហ័សក្នុងការអប់រំថ្នាក់ឧត្តមសិក្សា (Sol, 2021)។

ទោះបីជាម៉ាឡេស៊ីមានភាពរីកចម្រើនច្រើនផ្នែកបរិវត្តកម្មឌីជីថលក៏ដោយ ក៏ប្រទេសនេះនៅមានបញ្ហាប្រឈមក្នុងការធានាឱ្យមានសិទ្ធិទទួលបានការអប់រំប្រកបដោយសមធម៌ និងការដោះស្រាយបញ្ហាអភិបាលកិច្ច។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែប្រទេសម៉ាឡេស៊ីមានហេដ្ឋារចនាសម្ព័ន្ធ និងក្របខណ្ឌអភិបាលកិច្ចរឹងមាំ ប្រទេសនេះមានមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការសម្រេចការរីកចម្រើនផ្នែកឌីជីថលបន្ថែមទៀតនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា។ ម៉ាឡេស៊ីអាចប្រើប្រាស់ជំនាញ និងធនធានរបស់ខ្លួនដើម្បីគាំទ្រប្រទេសជិតខាងក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើបរិវត្តកម្មឌីជីថលរបស់ពួកគេ ដោយជំរុញកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងជំរុញការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សានៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ (Yoshino, 2021) (Sapuan & Roly, 2021)។

សរុបមក ខណៈពេលដែលប្រទេសឡាវ កម្ពុជា និងម៉ាឡេស៊ីប្រឈមមុខនឹងបញ្ហាប្រឈម និងឱកាសតាមកម្រិតផ្សេងៗគ្នានៅក្នុងដំណើរបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសរៀងៗខ្លួនក៏ដោយ

ប៉ុន្តែប្រទេសទាំងនេះមានទស្សនៈវិស័យរួមក្នុងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីលើកកម្ពស់លទ្ធផលអប់រំនៅថ្នាក់ឧត្តមសិក្សា និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គមឱ្យកាន់តែល្អប្រសើរ។ តាមរយៈការរួមគ្នាសហការដោះស្រាយបញ្ហាប្រឈមសំខាន់ៗ និងការចាប់យកឱកាសនវានុវត្តន៍ និងភាពជាដៃគូ ប្រទេសទាំងនេះអាចសម្រេចបាននូវសក្តានុពលពេញលេញនៃបរិវត្តកម្មឌីជីថលនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា និងត្រួសត្រាយផ្លូវដើម្បីអនាគតកាន់តែត្រចះត្រចង់សម្រាប់ប្រជាពលរដ្ឋរបស់ពួកគេ។

# 6 ការវិភាគបែបប្រៀបធៀប

## 6.1 ការប្រៀបធៀបកិច្ចខិតខំប្រឹងប្រែងនៃការធ្វើបរិវត្តកម្មឌីជីថល៖

នៅខែមករា ឆ្នាំ2023 អ្នកសិក្សាស្រាវជ្រាវមកពីសាកលវិទ្យាល័យ Universiti Teknologi Malaysia (UTM) បានធ្វើការវិភាគបែបប្រៀបធៀបទៅលើគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសឡាវ កម្ពុជា និងម៉ាឡេស៊ី។ ការពិនិត្យមើលយ៉ាងលម្អិតទៅលើចំណុចខុសគ្នានេះបានបង្ហាញអំពីភាពស្រដៀងគ្នា និងភាពខុសគ្នាជាច្រើននៅក្នុងវិធីសាស្រ្ត និងកម្រិតនៃជោគជ័យរបស់ប្រទេសទាំងបីនេះ។




*រូបភាពទី 2៖ ភាពស្រដៀងគ្នានៃការធ្វើបរិវត្តកម្មឌីជីថលសម្រាប់ប្រទេសកម្ពុជា ឡាវ និងម៉ាឡេស៊ី*

### 6.1.1 ភាពស្រដៀងគ្នា៖

i. **ការផ្ដោតលើការទទួលបាន៖** នៅទូទាំងប្រទេសឡាវ កម្ពុជា និងម៉ាឡេស៊ីមានគោលបំណងរួមក្នុងការពង្រីកលទ្ធភាពទទួលបានការអប់រំតាមរយៈមធ្យោបាយឌីជីថល។ ថ្នាលសិក្សាតាមប្រព័ន្ធអ៊ីនធឺណិត ថ្នាក់រៀនអនឡាញ និងបណ្ណាល័យឌីជីថលគឺជាគំនិតផ្ដួចផ្ដើមមួយចំនួននៅក្នុងចំណោមនោះ ដែលបានអនុវត្តដើម្បីចម្លុះឧបសគ្គផ្នែកភូមិសាស្ត្រ និងធានាបាននូវបរិយាបន្នអប់រំ ជាពិសេស នៅតាមតំបន់ដាច់ស្រយាល និងតំបន់មានការខ្វះខាត។

ii. **ការទទួលយកបច្ចេកវិទ្យា៖** ទោះបីជាមានកម្រិតខុសគ្នាផ្នែកហេដ្ឋារចនាសម្ព័ន្ធឌីជីថលក៏ដោយ ក៏ប្រទេសទាំងបីនេះបានបង្ហាញអំពីការប្ដេជ្ញាចិត្តក្នុងការទទួលយកបច្ចេកវិទ្យាដើម្បីបង្កើនប្រសិទ្ធភាពនៃការបង្រៀន ការសិក្សា និងដំណើរការរដ្ឋបាលនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា។ គំនិតផ្ដួចផ្ដើមគួរកត់សម្គាល់មួយចំនួន រួមមានដូចជា ឧបករណ៍វិភាគដំណើរការ AI មន្ទីរពិសោធន៍តាមអនឡាញ និងថ្នាលវាយតម្លៃឌីជីថល គឺបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ប្រទេសទាំងនេះក្នុងការស្វែងរកដំណោះស្រាយឌីជីថលដើម្បីឱ្យការអប់រំមានការរីកចម្រើន និងនវានុវត្តន៍។

iii. **ការកសាងសមត្ថភាព៖** ប្រទេសនីមួយៗទទួលស្គាល់ពីតួនាទីដ៏សំខាន់នៃអក្ខរកម្មឌីជីថល និងការអភិវឌ្ឍជំនាញក្នុងការជំរុញបរិវត្តកម្មឌីជីថលដោយជោគជ័យ។ កម្មវិធីបណ្ដុះបណ្ដាលដ៏រឹងមាំ សិក្ខាសាលា និងឱកាសអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈកំពុងត្រូវតែអនុវត្តដើម្បីបង្កើនសមត្ថភាពឌីជីថលរបស់អ្នកអប់រំ និងសិស្សនិស្សិត ដោយផ្ដល់ភាពអង់អាចឱ្យពួកគេប្រើប្រាស់ឧបករណ៍ និងធនធានឌីជីថលប្រកបដោយប្រសិទ្ធភាពក្នុងគោលបំណងអប់រំ។




*រូបភាពទី 3៖ ភាពខុសគ្នាផ្នែកបរិវត្តកម្មឌីជីថលរវាងកម្ពុជា ឡាវ និងម៉ាឡេស៊ី*

### 6.1.2 ភាពខុសគ្នា៖

i. **ហេដ្ឋារចនាសម្ព័ន្ធ៖** ខណៈពេលដែលម៉ាឡេស៊ីមានហេដ្ឋារចនាសម្ព័ន្ធឌីជីថលទំនើបជាងបើធៀបនឹងប្រទេសកម្ពុជា និងឡាវ ដែលសម្រួលដល់ការអនុវត្តកាន់តែរលូន និងការពង្រីកគំនិតផ្តួចផ្តើមឌីជីថលកាន់តែល្អប្រសើរ កម្ពុជា និងឡាវប្រឈមនឹងបញ្ហាប្រឈមសំខាន់ៗពាក់ព័ន្ធនឹងការតភ្ជាប់អ៊ីនធឺណិតមានកម្រិត ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ និងការទទួលបានបច្ចេកវិទ្យាក្នុងកម្រិតមិនស្មើគ្នានៅក្នុងប្រទេស។ ឧបសគ្គទាំងនេះអាចរាំងស្ទះដល់ប្រទេសទាំងនេះក្នុងការអនុវត្តកិច្ចខិតខំប្រឹងប្រែងបរិវត្តកម្មឌីជីថលឱ្យមានប្រសិទ្ធភាព និងការស្វែងដំណោះស្រាយមាននវានុវត្តន៍ដែលកែតម្រូវទៅតាមបរិបទក្នុងប្រទេស។

ii. **ការវិភាជន៍ធនធាន៖** ភាពខុសគ្នានៅក្នុងការវិភាជន៍ធនធានមានឥទ្ធិពលទៅលើវិសាលភាព និងការពង្រីកផ្តួចផ្តើមបរិវត្តកម្មឌីជីថលនៅទូទាំងប្រទេសទាំងបីនេះ។ ដោយទទួលបានផលប្រយោជន៍ពីការវិភាជន៍ថវិកាខ្ពស់ជាងសម្រាប់វិស័យអប់រំ និងធនធានសេដ្ឋកិច្ចរឹងមាំជាង ម៉ាឡេស៊ីអាចវិនិយោគកាន់តែមាននិរន្តរភាពលើការទទួលយកបច្ចេកវិទ្យា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការកសាងសមត្ថភាព។ ផ្ទុយទៅវិញ ដោយសារតែមានបញ្ហារាំងស្ទះដោយសារតែធនធានមានកម្រិត និងមានអាទិភាពប្រកួតប្រជែងពីវិស័យផ្សេង ប្រទេសកម្ពុជា

និងឡាវ ត្រូវតែផ្តល់អាទិភាពលើគំនិតផ្តួចផ្តើមដោយប្រុងប្រយ័ត្ន និងស្វែងរកវិធីសាស្ត្រដែលមានប្រសិទ្ធភាពថ្លៃចំណាយដើម្បីជំរុញបរិវត្តកម្មឌីជីថលដោយមានឧបសគ្គផ្នែកថវិកា។

iii. **បរិយាកាសគោលនយោបាយ៖** ភាពខុសគ្នាផ្នែកបរិយាកាសគោលនយោបាយក៏ជះឥទ្ធិពលទៅលើដំណើរនៃកិច្ចខិតខំប្រឹងប្រែងបរិវត្តកម្មឌីជីថលផងដែរ។ យុទ្ធសាស្ត្របរិវត្តកម្មឌីជីថលច្បាស់លាស់របស់ម៉ាឡេស៊ី ក្របខណ្ឌគោលនយោបាយមានការគាំទ្រ និងវិធីសាស្ត្រមានការសម្របសម្រួលនៅទូទាំងក្រសួងស្ថាប័នរដ្ឋាភិបាល និងគ្រឹះស្ថានឧត្តមសិក្សាបានជួយសម្រួលឱ្យប្រទេសនេះសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ផ្នែកឌីជីថលនីយកម្ម។ ផ្ទុយមកវិញ ប្រទេសកម្ពុជា និងឡាវប្រឈមមុខនឹងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងភាពស៊ីសង្វាក់ផ្នែកគោលនយោបាយ ក្របខណ្ឌបទប្បញ្ញត្តិ និងឧបសគ្គផ្នែកការិយាធិបតេយ្យ ដែលអាចរាំងស្ទះដល់ការបន្ស៊ីគំនិតផ្តួចផ្តើមឌីជីថលជាមួយនឹងគោលដៅអភិវឌ្ឍន៍ជាតិកាន់តែទូលំទូលាយ។

## 6.2 មេរៀនពិសោធន៍ និងឧត្តមានុវត្តន៍៖

ដោយផ្អែកលើលទ្ធផលនៃការវិភាគ របាយការណ៍នេះបង្ហាញអំពីមេរៀនពិសោធន៍ និងឧត្តមានុវត្តន៍ដ៏មានតម្លៃជាច្រើន ដែលផ្តល់ការណែនាំដ៏មានតម្លៃសម្រាប់កិច្ចខិតខំប្រឹងប្រែងបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសកម្ពុជា និងឡាវ។

i. **ការចូលរួមរបស់ភាគីពាក់ព័ន្ធ៖** ការចូលរួមរបស់ភាគីពាក់ព័ន្ធនៅគ្រប់កម្រិត រួមទាំងក្រសួងស្ថាប័នរដ្ឋាភិបាល គ្រឹះស្ថានអប់រំ ដៃគូឧស្សាហកម្ម និងសហគមន៍ គឺជាកត្តាដ៏សំខាន់បំផុតដើម្បីអនុវត្តគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលឱ្យបានជោគជ័យ។ ភាពជាដៃគូសហការក៏ជំរុញឱ្យមាននវានុវត្តន៍ ការចែករំលែកធនធាន និងការដោះស្រាយបញ្ហារួម ដោយលើកកម្ពស់លទ្ធផលកាន់តែមានឥទ្ធិពល និងប្រកបដោយនិរន្តរភាព។




*រូបភាពទី 4៖ ការចូលរួមរបស់ភាគីពាក់ព័ន្ធ*

ii. **ការសម្របខ្លួន និងភាពបត់បែន៖** ភាពបត់បែនក្នុងវិធីសាស្ត្រ និងការសម្របខ្លួនទៅតាមកាលៈទេសៈដែលកំពុងមានការប្រែប្រួល គឺសំខាន់ខ្លាំងណាស់សម្រាប់ដោះស្រាយជាមួយនឹងភាពស្មុគស្មាញនៃបរិវត្តកម្មឌីជីថល។ បណ្តាប្រទេសនានាត្រូវមានឆន្ទៈអនុវត្តឡើងវិញ ធ្វើពិសោធន៍ និងកែសម្រួលយុទ្ធសាស្ត្ររបស់ខ្លួនដោយផ្អែកលើតម្រូវការដែលកំពុងវិវត្តឥត

ឈប់ឈរ បច្ចេកវិទ្យាថ្មីៗ និងមតិត្រលប់ពីភាគីពាក់ព័ន្ធ។ វប្បធម៌នវានុវត្តន៍ និងការកែលម្អជាបន្តបន្ទាប់ ជំរុញឱ្យមានភាពធន់ និងការសម្រេចបាននូវវឌ្ឍនភាពនៅក្នុងយុគសម័យឌីជីថលនេះ។




*រូបភាពទី 5៖ ការសម្របខ្លួន និងភាពបត់បែន*

iii. **ការកសាងសមត្ថភាព៖** ការវិនិយោគលើកម្មវិធីកសាងសមត្ថភាពដើម្បីពង្រឹងអក្ខរកម្ម និងជំនាញឌីជីថលដល់សាស្ត្រាចារ្យ និងសិស្សនិស្សិត គឺជាមូលដ្ឋានគ្រឹះនៃបរិវត្តកម្មឌីជីថលប្រកបដោយនិរន្តរភាព។ ការបណ្តុះបណ្តាលបន្ត និងឱកាសអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈផ្តល់ភាពអង់អាចដល់ភាគីពាក់ព័ន្ធក្នុងការបន្តទទួលយកនូវការរីកចម្រើននៃបច្ចេកវិទ្យា កសាងទំនុកចិត្តក្នុងការប្រើប្រាស់ឧបករណ៍ឌីជីថល និងសម្រេចបាននូវសក្តានុពលពេញលេញក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្នុងគោលបំណងអប់រំ។




*រូបភាពទី 6៖ ការកសាងសមត្ថភាព*

iv. **ការបន្ស៊ីគោលនយោបាយ៖** ការបង្កើតក្របខណ្ឌគោលនយោបាយច្បាស់លាស់ និងគោលការណ៍ណែនាំផ្លូវច្បាប់ ដែលផ្តល់ការគាំទ្រដល់បរិវត្តកម្មឌីជីថលគឺជាកត្តាដ៏សំខាន់ដើម្បីបង្កើតបរិយាកាសអំណោយផល។ គោលនយោបាយនានាគួរតែផ្តល់អាទិភាពដល់លទ្ធភាពទទួលបាន តម្លៃសមរម្យ ភាពឯកជន និងសន្តិសុខទិន្នន័យ ខណៈដែលជំរុញដល់នវានុវត្តន៍ ភាពប្រកួតប្រជែង និងការសហការគ្នានៅក្នុងប្រព័ន្ធអេកូឌីជីថល។ ភាពស៊ីសង្វាក់គ្នា និងការបន្ស៊ីគោលនយោបាយឱ្យស្របតាមគោលដៅអភិវឌ្ឍន៍ជាតិដ៏ទូលំទូលាយ គឺជាកត្តាដ៏សំខាន់ជាសារវ័ន្តដើម្បីជំរុញវឌ្ឍនភាព និងបង្កើនឥទ្ធិពលជាអតិបរមានៃគំនិតផ្តួចផ្តើមឌីជីថល។




*រូបភាពទី 7៖ ការបន្សុីគោលនយោបាយ*

ការអនុវត្តទាំងនេះគឺពុំមានភាពចាំបាច់សម្រាប់ម៉ាឡេស៊ីនោះទេ ដោយសារតែប្រទេសនេះមានគោលនយោបាយពាក់ព័ន្ធរួចអស់ហើយ។ តាមរយៈការដកស្រង់មេរៀនពិសោធន៍ និងឧត្តមានុវត្តន៍ទាំងនេះ បណ្តាប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍អាចពន្លឿនដំណើរបរិវត្តកម្មឌីជីថលបាន តភ្ជាប់គម្លាតឌីជីថល និងសម្រេចបាននូវសក្តានុពលពេញលេញរបស់បច្ចេកវិទ្យាដើម្បីបង្កើនលទ្ធផលសិក្សានៅថ្នាក់ឧត្តមសិក្សា ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងផ្តល់ភាពអង់អាចដល់បុគ្គល និងសហគមន៍នៅទូទាំងតំបន់។ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តកិច្ចការទាំងនេះ និងការអនុវត្តគោលនយោបាយបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសម៉ាឡេស៊ី ប្រទេសនេះមានវិធានការមួយដូចខាងក្រោមសម្រាប់ប្រទេសផ្សេងៗយកទៅធ្វើការពិចារណា៖

i. **ការវិភាជន៍ធនធានឱ្យបានគ្រប់គ្រាន់៖** ធានាថាមានការវិភាជន៍ថវិកាប្រកបដោយប្រសិទ្ធភាព បុគ្គលិកជំនាញ និងបច្ចេកវិទ្យាសមស្របដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយបរិវត្តកម្មឌីជីថល។

ii. **ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល៖** បន្តធ្វើការវិនិយោគទៅលើការកែលម្អប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) ដូចជា ការពង្រីកការតភ្ជាប់អ៊ីនធឺណិតល្បឿនលឿន និងការអភិវឌ្ឍមជ្ឈមណ្ឌលទិន្នន័យ។

iii. **ការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញ៖** អនុវត្តកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍ជំនាញដើម្បីបំពាក់បំប៉នសមត្ថភាពដែលត្រូវការជាចាំបាច់ដល់ធនធានមនុស្សក្នុងការទទួលយក និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យមានប្រសិទ្ធភាព។

iv. **ការលើកកម្ពស់នវានុវត្តន៍ និងកិច្ចសហការ៖** លើកទឹកចិត្តដល់នវានុវត្តន៍ និងកិច្ចសហការរវាងវិស័យសាធារណៈ វិស័យឯកជន គ្រឹះស្ថានសិក្សា និងសង្គមស៊ីវិលដើម្បីជំរុញការអភិវឌ្ឍ និងការអនុវត្តដំណោះស្រាយឌីជីថលឱ្យមានប្រសិទ្ធភាព។

v. **ការត្រួតពិនិត្យ និងការវាយតម្លៃជាបន្តបន្ទាប់៖** បង្កើតយន្តការត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីធ្វើការតាមដានវឌ្ឍនភាពនៃការអនុវត្តគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថល កំណត់ផ្នែកត្រូវធ្វើការកែលម្អ និងកែសម្រួលយុទ្ធសាស្ត្រទៅតាមតម្រូវការជាក់ស្តែង។

vi. **ការចូលរួមរបស់ពហុភាគីពាក់ព័ន្ធ៖** ជំរុញឱ្យមានការចូលរួមយ៉ាងសកម្ម និងការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំង ប្រជាពលរដ្ឋ ធុរកិច្ច និងគ្រឹះស្ថានសិក្សា ឱ្យចូលរួមនៅក្នុងដំណើរបរិវត្តកម្មឌីជីថលដើម្បីធានានូវការទទួលយកបច្ចេកវិទ្យាឌីជីថលឱ្យបានទូលំទូលាយ និងប្រកបដោយនិរន្តរភាព។

vii. **ការអនុម័តបទដ្ឋាន និងឧត្តមានុវត្តន៍អន្តរជាតិ៖** ប្រើប្រាស់បទដ្ឋាន និងឧត្តមានុវត្តន៍អន្តរជាតិនៅក្នុងបរិវត្តកម្មឌីជីថលដើម្បីជាឯកសារ និងការណែនាំសម្រាប់ការតាក់តែងគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ម៉ាឡេស៊ី។

viii. តាមរយៈការអនុវត្តវិធានការទាំងនេះ ម៉ាឡេស៊ី និងប្រទេសផ្សេងទៀត រួមមាន ឡាវ និង កម្ពុជា អាចដោះស្រាយបញ្ហាប្រឈមប្រកបដោយប្រសិទ្ធភាព និងបង្កើនវឌ្ឍនភាពឆ្ពោះទៅរកបរិវត្តកម្មឌីជីថលប្រកបដោយជោគជ័យ ដោយអាចផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ច សង្គម និងរដ្ឋាភិបាលទាំងមូល។

# 7 បញ្ហាប្រឈមក្នុងការពន្លឿនការធ្វើបរិវត្តកម្មឌីជីថល

## 7.1 រចនាសម្ព័ន្ធមានកម្រិត៖

បញ្ហាប្រឈមដោយសារតែហេដ្ឋារចនាសម្ព័ន្ធមានកម្រិតបង្កឱ្យមានឧបសគ្គជាច្រើន ដែលរាំងស្ទះដល់ការរួមបញ្ចូលបច្ចេកវិទ្យាឌីជីថលទៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា។ នៅក្នុងតំបន់ជាច្រើន ជាពិសេស នៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាលតែម្តង ការទទួលបានការតភ្ជាប់អ៊ីនធឺណិតដែលមានស្ថិរភាពនៅតែជាឧបសគ្គខ្លាំងនៅឡើយ។ ទំហំអ៊ីនធឺណិត (bandwidth) មានកម្រិត និងល្បឿនអ៊ីនធឺណិតយឺត និងការដាច់អ៊ីនធឺណិតជាញឹកញាប់ គឺជាកត្តារាំងស្ទះដល់ការផ្តល់ការអប់រំតាមប្រព័ន្ធអ៊ីនធឺណិតប្រកបដោយប្រសិទ្ធភាព ដែលបន្ថយបង្អាក់ដល់សមត្ថភាពរបស់សិស្សនិស្សិតក្នុងការចូលរួមនៅក្នុងថ្នាក់អនឡាញ ការចូលប្រើប្រាស់ធនធានឌីជីថល និងការចូលរួមនៅក្នុងសកម្មភាពសិក្សារួមគ្នា ជាដើម។ ជាងនេះទៅទៀត ការទទួលបានសេវាអគ្គិសនី និងឧបករណ៍ឌីជីថលមិនគ្រប់គ្រាន់បានធ្វើឱ្យបញ្ហាទាំងនេះកាន់តែមានសភាពធ្ងន់ធ្ងរខ្លាំងឡើង ដោយបង្កជាការលំបាកកាន់តែខ្លាំងសម្រាប់សិស្សនិស្សិតណាដែលមានជីវភាពខ្វះខាត និងពុំមានឧបករណ៍ដែលត្រូវការចាំបាច់ដើម្បីចូលរួមនៅក្នុងការសិក្សាតាមអ៊ីនធឺណិតឱ្យដូចសិស្សផ្សេងទៀត។

ការដោះស្រាយបញ្ហាហេដ្ឋារចនាសម្ព័ន្ធមានកម្រិត គឺទាមទារឱ្យមានវិធីសាស្ត្រពហុភាគី ដែលរាប់បញ្ចូលទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងឌីជីថល។ រដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងភាគីពាក់ព័ន្ធក្នុងវិស័យឯកជនត្រូវតែសហការគ្នាដើម្បីពង្រីកបណ្តាញតភ្ជាប់អ៊ីនធឺណិត ធ្វើ

ឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត និងប្រើប្រាស់ដំណោះស្រាយមាននវានុវត្តន៍ ដូចជា បច្ចេកវិទ្យាអ៊ីនធឺណិតផ្កាយរណប ដើម្បីអាចគ្របដណ្តប់ដល់តំបន់ដាច់ស្រយាល និងតំបន់ដែលមានការខ្វះខាត។ លើសពីនេះ គំនិតផ្តួចផ្តើមក្នុងការផ្តល់នូវលទ្ធភាពទទួលបានឧបករណ៍ឌីជីថលក្នុងតម្លៃសមរម្យ និងបរិយាកាសសិក្សាតាមបច្ចេកវិទ្យា គឺជាកត្តាដ៏សំខាន់ជាសារវន្តដើម្បីធានានូវលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌សម្រាប់អ្នកសិក្សាទាំងអស់។ គម្រោងដឹកនាំដោយសហគមន៍ ភាពជាដៃគូរវាងរដ្ឋ និងឯកជន និងការឧបត្ថម្ភធនរបស់រដ្ឋាភិបាល អាចជួយសម្រួលដល់ការបំពេញគម្លាតឌីជីថល និងបង្កើតប្រព័ន្ធអេកូអប់រំប្រកបដោយបរិយាបន្ន ដែលសិស្សគ្រប់រូបអាចមានការរីកចម្រើនបានគ្រប់គ្នា។




*រូបភាពទី 8៖ ដំណោះស្រាយនវានុវត្តន៍*

## 7.2 មូលនិធិ និងការវិនិយោគ៖

ការធានាឱ្យបាននូវការផ្តល់មូលនិធិ និងការវិនិយោគគ្រប់គ្រាន់សម្រាប់គំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលគឺជាបញ្ហាប្រឈមដែលគ្រឹះស្ថានអប់រំនៅទូទាំងពិភពលោកបាន និងកំពុងជួបប្រទះអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ការវិភាជន៍ថវិកាមានកម្រិត អាទិភាពមូលនិធិមានការប្រកួតប្រជែងដោយវិស័យផ្សេង និងកង្វះខាតធនធានជាទូទៅគឺជាកត្តារាំងស្ទះដល់ការអនុវត្តយុទ្ធសាស្ត្រឌីជីថលដ៏ទូលំទូលាយ និងការធ្វើឱ្យប្រសើរនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ។ ការចំណាយជាមុនពាក់ព័ន្ធនឹងលទ្ធកម្មបច្ចេកវិទ្យា ការទិញអាជ្ញាបណ្ណកម្មវិធីសូហ្វវែរ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការបណ្តុះបណ្តាលបុគ្គលិកបន្ថែមទៀត គឺជាឧបសគ្គផ្នែកថវិការបស់គ្រឹះស្ថានអប់រំទាំងឡាយ ដែលធ្វើឱ្យមានការលំបាកក្នុងការទ្រទ្រង់ដល់កិច្ចខិតខំប្រឹងប្រែងធ្វើបរិវត្តកម្មឌីជីថលរយៈពេលវែង។

ដើម្បីដោះស្រាយបញ្ហាប្រឈមផ្នែកថវិកា រដ្ឋាភិបាលនានាត្រូវតែផ្តល់អាទិភាពដល់ការចំណាយលើវិស័យអប់រំ និងវិភាជមូលនិធិបម្រុងសម្រាប់តែគម្រោងបរិវត្តកម្មឌីជីថលនៅក្នុង

ការអប់រំថ្នាក់ឧត្តមសិក្សា។ អង្គការអន្តរជាតិ មូលនិធិសប្បុរសធម៌ និងដៃគូវិស័យឯកជនក៏អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ និងការផ្តល់ជំនួយឥតសំណងអាហារូបករណ៍ និងមូលនិធិស្រាវជ្រាវដើម្បីគាំទ្រនវានុវត្តន៍ឌីជីថល និងការកសាងសមត្ថភាពក្នុងការអប់រំថ្នាក់ឧត្តមសិក្សាផងដែរ។ ជាងនេះទៅទៀត ការស្វែងរកយន្តការហិរញ្ញវត្ថុមាននវានុវត្តន៍ ដូចជា ការវិនិយោគមានឥទ្ធិពល ការវិនិយោគរួមទុន និងការរៃអង្គាសថវិកាក៏អាចប្រមូលប្រភពមូលនិធិបន្ថែមសម្រាប់ទ្រទ្រង់ដល់គំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលបានដែរ។ តាមរយៈការវិនិយោគជាយុទ្ធសាស្ត្រទៅលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការបង្កើតកម្មវិធីកសាងសមត្ថភាព និងដំណោះស្រាយសិក្សាតាមបច្ចេកវិទ្យា បណ្តាប្រទេសនានាអាចធានាបានថាសិស្សនិស្សិតគ្រប់រូបអាចទទួលបានការអប់រំដែលមានគុណភាព និងឱកាសជោគជ័យក្នុងយុគសម័យឌីជីថលនាពេលបច្ចុប្បន្ននេះ។




*រូបភាពទី 9៖ ការផ្តល់មូលនិធិ និងការវិនិយោគ*

## 7.3 **គម្លាតអក្ខរកម្ម និងជំនាញឌីជីថល៖**

គម្លាតអក្ខរកម្ម និងជំនាញឌីជីថលក្នុងចំណោមអ្នកអប់រំ សិស្សនិស្សិត និងបុគ្គលិករដ្ឋបាលបង្កឱ្យមានបញ្ហាប្រឈមយ៉ាងខ្លាំងដល់ការអនុវត្តគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលប្រកបដោយប្រសិទ្ធភាពនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា។ អ្នកអប់រំជាច្រើនពុំមានសមត្ថភាពគ្រប់គ្រាន់ដែលជាតម្រូវការចាំបាច់ក្នុងការរួមបញ្ចូលបច្ចេកវិទ្យាឱ្យបានរលូននៅក្នុងការអនុវត្តការបង្រៀន ការរៀបចំឱ្យមានបទពិសោធន៍សិក្សាតាមអ៊ីនធឺណិតដែលមានការចូលរួមពីសិស្ស និងការប្រើប្រាស់ការវិភាគទិន្នន័យសម្រាប់ការសម្រេចចិត្ត ជាដើម។ ស្រដៀងគ្នានេះដែរ សិស្សនិស្សិតអាចមានឧបសគ្គជាមួយនឹងជំនាញអក្ខរកម្មឌីជីថលកម្រិតមូលដ្ឋាន ដូចជា ការរុករក

នៅលើថ្នាលអនឡាញ ការវាយតម្លៃមាតិកាឌីជីថលឱ្យបានស៊ីជម្រៅ និងការសហការដោយប្រសិទ្ធភាពនៅក្នុងបរិយាកាសសិក្សាតាមអនឡាញ។

ការបំពេញគម្លាតអក្ខរកម្ម និងជំនាញឌីជីថលតម្រូវឱ្យមានគំនិតផ្តួចផ្តើមកសាងសមត្ថភាពគោលដៅ ការរៀបចំបង្កើតកម្មវិធីអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈ និងការបណ្តុះបណ្តាលជាបន្តបន្ទាប់ដល់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងប្រព័ន្ធអេកូអប់រំ។ គ្រឹះស្ថានសិក្សានានាត្រូវតែវិនិយោគទៅលើការរៀបចំសិក្ខាសាលាអភិវឌ្ឍន៍សមត្ថភាពសាស្ត្រាចារ្យ វគ្គសិក្សាតាមអ៊ីនធឺណិត និងកម្មវិធីផ្តល់វិញ្ញាបនបត្រ ដើម្បីបំពាក់បំប៉នដល់អ្នកអប់រំនូវចំណេះដឹងគរុកោសល្យ និងជំនាញបច្ចេកទេសដែលត្រូវការជាចាំបាច់ដើម្បីប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាពក្នុងការបង្រៀនសិស្ស។ ស្រដៀងគ្នានេះដែរ សិស្សនិស្សិតគួរតែទទួលបានការបណ្តុះបណ្តាលផ្នែកអក្ខរកម្មឌីជីថល ការត្រិះរិះពិចារណា និងអក្ខរកម្មព័ត៌មាន ដើម្បីបំពាក់បំប៉នពួកគេនូវជំនាញចាំបាច់ដើម្បីរីកចម្រើននៅក្នុងយុគសម័យឌីជីថល។ ជាងនេះទៅទៀត ការជំរុញវប្បធម៌នៃការសិក្សាពេញមួយជីវិត និងភាពស្ទាត់ជំនាញផ្នែកឌីជីថល គឺជាកត្តាដ៏ចាំបាច់ដើម្បីធានាថានិស្សិតបញ្ចប់ការសិក្សាត្រូវបានរៀបចំឱ្យមានលក្ខណៈគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការកម្លាំងពលកម្មនៅសតវត្សរ៍ទី 21 ហើយអាចសម្របខ្លួនទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាយ៉ាងឆាប់រហ័ស។




*រូបភាពទី 10៖ គម្លាតអក្ខរកម្មឌីជីថល និងជំនាញ*

## 7.4 បរិយាកាសគោលនយោបាយ និងបទប្បញ្ញត្តិ៖

បរិយាកាសគោលនយោបាយ និងបទប្បញ្ញត្តិដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំដំណើរបរិវត្តកម្មឌីជីថលនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា។ ក្របខណ្ឌបទប្បញ្ញត្តិមានភាពស្មុគស្មាញ គោលនយោបាយមិនត្រូវនឹងសម័យកាល និងឧបសគ្គផ្នែកការិយាធិបតេយ្យអាចរាំងស្ទះដល់នវានុវត្តន៍ ការសហការ និងការធ្វើពិសោធន៍ជាមួយនឹងបច្ចេកវិទ្យាឌីជីថលថ្មីៗ និងវិធីសាស្ត្រ

គរុកោសល្យ។ គោលនយោបាយមិនស៊ីសង្វាក់គ្នានៅទូទាំងក្រសួងស្ថាប័នរដ្ឋាភិបាល និងយុត្តាធិការផ្សេងៗអាចបង្កើតភាពស្រពិចស្រពិល និងភាពមិនច្បាស់លាស់ ដែលរារាំងដល់ការវិនិយោគ និងក្លាយជាឧបសគ្គដល់វឌ្ឍនភាព។

ដើម្បីជំរុញបរិយាកាសអំណោយផលសម្រាប់បរិវត្តកម្មឌីជីថល អ្នករៀបចំគោលនយោបាយត្រូវតែអនុវត្តគោលនយោបាយច្បាស់លាស់ មានភាពបត់បែន និងសម្របខ្លួន ដែលលើកកម្ពស់ដល់នវានុវត្តន៍ ការពារឯកជនភាពទិន្នន័យ ធានានូវសិទ្ធិឌីជីថល និងជំរុញការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអប់រំ។ លើសពីនេះ ក្របខណ្ឌបទប្បញ្ញត្តិក៏គួរតែឆ្លើយតបទៅនឹងភាពជឿនលឿននៃបច្ចេកវិទ្យា និងនិន្នាការដែលកំពុងលេចចេញជារូបរាងនៅក្នុងការសិក្សាតាមប្រព័ន្ធឌីជីថល ដែលអាចឱ្យគ្រឹះស្ថានសិក្សាមានភាពបត់បែនក្នុងការធ្វើពិសោធន៍ជាមួយវិធីសាស្ត្របង្រៀនប្រកបដោយភាពច្នៃប្រឌិត យុទ្ធសាស្ត្រវាយតម្លៃ និងម៉ូដែលនៃការបញ្ជាក់គុណវុឌ្ឍិ។ អ្នករៀបចំគោលនយោបាយគួរតែចូលរួមជាមួយភាគីពាក់ព័ន្ធមកពីវិស័យអប់រំ ឧស្សាហកម្ម សង្គមស៊ីវិល និងគ្រឹះស្ថានសិក្សានានានៅក្នុងដំណើរការរៀបចំតាក់តែង គោលនយោបាយ ដើម្បីធានាថាគោលនយោបាយទាំងនោះឆ្លុះបញ្ចាំងពីតម្រូវការ និងសេចក្តីប្រាថ្នារបស់ភាគីពាក់ព័ន្ធទាំងអស់ ព្រមទាំងលើកកម្ពស់ការទទួលបានការអប់រំប្រកបដោយគុណភាព និងសមធម៌សម្រាប់ទាំងអស់គ្នា។

ជាចុងក្រោយ ការដោះស្រាយបញ្ហាប្រឈមកាន់តែទូលំទូលាយផ្នែកហេដ្ឋារចនាសម្ព័ន្ធ មានកម្រិត កង្វះថវិកា គម្លាតអក្ខរកម្មឌីជីថល និងភាពស្មុគស្មាញនៃគោលនយោបាយ គឺជាកិច្ចការដ៏សំខាន់ដើម្បីពន្លឿនការធ្វើបរិវត្តកម្មឌីជីថលនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា។ តាមរយៈការទទួលយកវិធីសាស្ត្រគ្រប់ជ្រុងជ្រោយដែលពាក់ព័ន្ធនឹងការវិនិយោគជាយុទ្ធសាស្ត្រទៅលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល គំនិតផ្តួចផ្តើមកសាងសមត្ថភាព និងកំណែទម្រង់គោលនយោបាយ ប្រទេសនានាអាចសម្រេចបាននូវសក្តានុពលនៃបរិវត្តកម្មន៍បច្ចេកវិទ្យា និងបង្កើតបាននូវប្រព័ន្ធអេកូអប់រំថ្នាក់ឧត្តមសិក្សាប្រកបដោយបរិយាបន្ន សមធម៌ និងដំណើរការដោយប្រព័ន្ធឌីជីថល ដែលផ្តល់ផ្តល់លទ្ធភាពដល់អ្នកសិក្សាឱ្យរីកចម្រើននៅក្នុងយុគសម័យឌីជីថល។




*រូបភាពទី 11៖ បរិយាកាសគោលនយោបាយ និងបទប្បញ្ញត្តិ*

## 8 យុទ្ធសាស្ត្រពន្លឿនការធ្វើបរិវត្តកម្មឌីជីថល

ពិតប្រាកដណាស់ យើងទាំងអស់គ្នាត្រូវតែស្វែងយល់ឱ្យកាន់តែស៊ីជម្រៅអំពីវិធីសាស្ត្រដែលកែតម្រូវទៅតាមតម្រូវការដើម្បីពន្លឿនការធ្វើបរិវត្តកម្មឌីជីថលនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សានៅប្រទេសម៉ាឡេស៊ី ឡាវ និងកម្ពុជា (Lee, 2007)។

### 8.1 ប្រទេសម៉ាឡេស៊ី

ដោយសារតែមានហេដ្ឋារចនាសម្ព័ន្ធឌីជីថលជឿនលឿន ប្រទេសម៉ាឡេស៊ីអាចផ្តោតសំខាន់លើការកែលម្អ និងបង្កើនប្រសិទ្ធភាពនៃគំនិតផ្តួចផ្តើមការអប់រំឌីជីថលដែលមានស្រាប់ ដែលកត្តានេះអាចរួមមាន ការបង្កើតកម្មវិធីបណ្តុះបណ្តាលឌីជីថលដាច់ដោយឡែកដែលត្រូវបានរចនាឡើងជាពិសេសសម្រាប់គ្រឹះស្ថានឧត្តមសិក្សា។ កម្មវិធីនេះគួរតែរួមបញ្ចូលមិនត្រឹមតែការធ្វើឱ្យប្រសើរឡើងផ្នែកបច្ចេកវិទ្យា ដូចជា ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការផ្តល់នូវលទ្ធភាពក្នុងការទទួលបានបច្ចេកវិទ្យាអប់រំទំនើបប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់កិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពគ្រប់ជ្រុងជ្រោយផងដែរ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះគួរតែមានគោលបំណងលើកកម្ពស់អក្ខរកម្ម និងជំនាញឌីជីថលទាំងសម្រាប់សិស្សនិស្សិត និងសាស្ត្រាចារ្យ។ កម្មវិធីបណ្តុះបណ្តាលអាចគ្របដណ្តប់លើប្រធានបទជាច្រើន រួមមានគរុកោសល្យឌីជីថល វិធីសាស្ត្របង្រៀនតាមអ៊ីនធឺណិត ឧបករណ៍បច្ចេកវិទ្យាអប់រំ និងការវិភាគទិន្នន័យសម្រាប់ការសម្រេចចិត្តអប់រំ ជាដើម។ លើសពីនេះ ការបណ្តុះបណ្តាលជំនាញអាចផ្តល់ជូនដល់អ្នកអប់រំដើម្បីបង្កើតបទពិសោធន៍សិក្សាឌីជីថលដែលទាក់ទាញ និងមានអន្តរកម្មទៅវិញទៅមក។ កិច្ចសហការជាមួយដៃគូឧស្សាហកម្មក៏អាចជួយសម្រួលដល់ការរួមបញ្ចូលជំនាញពាក់ព័ន្ធនឹងឧស្សាហកម្មនៅក្នុងកម្មវិធីសិក្សា ដោយធានាបានថានិស្សិតបញ្ចប់ការសិក្សាត្រូវបានបំពាក់បំប៉នដោយសមត្ថភាពដែលត្រូវការដើម្បីក្លាយជាធនធានជំនាញផ្នែកឌីជីថល។

### 8.2 ប្រទេសកម្ពុជា

នៅក្នុងប្រទេសកម្ពុជា ដែលហេដ្ឋារចនាសម្ព័ន្ធ និងធនធានឌីជីថលអាចមានកម្រិតជាងបើប្រៀបធៀបទៅនឹងប្រទេសម៉ាឡេស៊ី យុទ្ធសាស្ត្រគួរតែផ្តល់អាទិភាពដល់ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងការកែលម្អលទ្ធភាពទទួលបានធនធានឌីជីថល។ គំនិតផ្តួចផ្តើមអាច រួមមានការពង្រីកការតភ្ជាប់អ៊ីនធឺណិតទៅកាន់តំបន់ដែលមានការលំបាកខ្លាំង ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅក្នុងបរិវេណសាកលវិទ្យាល័យ និងការលើកកម្ពស់លទ្ធភាពប្រើប្រាស់ឧបករណ៍សម្រាប់សិស្សនិស្សិត។ ជាងនេះទៅទៀត ការរួមបញ្ចូលអក្ខរកម្មឌីជីថលទៅក្នុងកម្មវិធីសិក្សាចាប់តាំងពីដំណាក់កាលដំបូងអាចជួយសិស្សឱ្យអភិវឌ្ឍជំនាញសំខាន់ៗសម្រាប់

ក្នុងការស្វែងយល់នៅក្នុងពិភពឌីជីថល។ កម្មវិធីអភិវឌ្ឍន៍មហាវិទ្យាល័យគួរតែត្រូវបានបង្កើតឡើងដើម្បីផ្តល់ជូនអ្នកអប់រំនូវជំនាញគរុកោសល្យ និងបច្ចេកវិទ្យាដែលត្រូវការជាចាំបាច់ដើម្បីដាក់បញ្ចូលឧបករណ៍ឌីជីថលដោយប្រសិទ្ធភាពទៅក្នុងការអនុវត្តការបង្រៀនរបស់ពួកគេ។ កម្មវិធីទាំងនេះអាចផ្តោតលើការបណ្តុះបណ្តាលអ្នកអប់រំឱ្យចេះប្រើប្រាស់ថ្នាលសិក្សាឌីជីថល វិធីសាស្ត្រវាយតម្លៃតាមអ៊ីនធឺណិត និងការបង្កើតមាតិកាពហុបណ្តាញផ្សព្វផ្សាយ ជាដើម។ ភាពជាដៃគូជាមួយអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនវិស័យឯកជនក៏អាចផ្តល់នូវធនធាន និងជំនាញដ៏មានតម្លៃ ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមការអប់រំឌីជីថលនៅក្នុងប្រទេសកម្ពុជាបានផងដែរ។

### 8.3 ប្រទេសឡាវ

ដូចគ្នាទៅនឹងប្រទេសកម្ពុជាដែរ ប្រទេសឡាវក៏អាចត្រូវការការវិនិយោគដ៏សំខាន់ទៅលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពដើម្បីពន្លឿនបរិវត្តកម្មឌីជីថលនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សាដែរ។ ការផ្តល់អាទិភាពដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជា ការពង្រីកការតភ្ជាប់អ៊ីនធឺណិត និងការធ្វើទំនើបកម្ម ហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅក្នុងបរិវេណសាកលវិទ្យាល័យ អាចជាការកសាង មូលដ្ឋានគ្រឹះសម្រាប់គំនិតផ្តួចផ្តើមការអប់រំឌីជីថលនៅក្នុងប្រទេសនេះ។ ទន្ទឹមនឹងនេះ គួរមានកិច្ចខិតខំប្រឹងប្រែងដើម្បីដាក់បញ្ចូលអក្ខរកម្មឌីជីថលទៅក្នុងកម្មវិធីសិក្សា និងផ្តល់កម្មវិធីអភិវឌ្ឍន៍មហាវិទ្យាល័យដើម្បីបង្កើនជំនាញបង្រៀនឌីជីថលរបស់អ្នកអប់រំ។ លើសពីនេះទៀត ការបង្កើតមជ្ឈមណ្ឌលនវានុវត្តន៍ និងជំរុញកិច្ចសហការជាមួយភាគីពាក់ព័ន្ធនៅក្នុងវិស័យឧស្សាហកម្ម និងភាគីពាក់ព័ន្ធនៅក្នុងក្រសួងស្ថាប័នរដ្ឋាភិបាល អាចជំរុញនវានុវត្តន៍ឌីជីថល និងជំរុញវឌ្ឍនភាពនៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា។ មជ្ឈមណ្ឌលនវានុវត្តន៍ទាំងនេះអាចក្លាយជាមជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវ ការធ្វើពិសោធន៍ និងកិច្ចសហការ ដែលសិស្សនិស្សិត មហាវិទ្យាល័យ និងដៃគូឧស្សាហកម្មអាចធ្វើការរួមគ្នាទៅលើគម្រោងនវានុវត្តន៍ ដែលដោះស្រាយបញ្ហាប្រឈមនៅក្នុងមូលដ្ឋាន និងរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ជាតិ។

សរុបមក វិធីសាស្ត្រកែសម្រួលទៅតាមតម្រូវការដើម្បីពន្លឿនការធ្វើបរិវត្តកម្មឌីជីថលក្នុងការអប់រំថ្នាក់ឧត្តមសិក្សានៅក្នុងប្រទេសម៉ាឡេស៊ី ឡាវ និងកម្ពុជា គួរតែពិចារណាទៅលើពីបញ្ហាប្រឈម និងឱកាសពិសេសខុសប្លែកពីគ្នាដែលមាននៅក្នុងប្រទេសនីមួយៗ។ តាមរយៈការផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ កិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាព និងកិច្ចសហការជាមួយភាគីពាក់ព័ន្ធនានា ប្រទេសទាំងបីនេះអាចបង្កើតប្រព័ន្ធអេកូអប់រំថ្នាក់ឧត្តមសិក្សាប្រកបដោយបរិយានបន្ទ នវានុវត្តន៍ និងដំណើរការដោយប្រព័ន្ធឌីជីថល ផ្តល់ផ្តល់អត្ថប្រយោជន៍បន្ថែមទៀតដល់សិស្សនិស្សិត អ្នកអប់រំ និងសង្គមដូចដែលករណីសិក្សានេះបានលើកឡើង។

# 9 ករណីសិក្សា

ចំពោះ WPS2 យើងបានផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការប្រមូល និងវិភាគទិន្នន័យ ក្នុងគោលបំណងស្វែងរកព័ត៌មានលម្អិត និងស៊ីជម្រៅអំពីទិដ្ឋភាពផ្សេងៗគ្នានៃគម្រោង។ សំណុំទិន្នន័យគ្រប់ជ្រុងជ្រោយបានបង្កើតឡើង បែងចែកទៅតាមប្រទេស និងរវាងនិស្សិត និងបុគ្គលិក ដែលបានសម្របសម្រួលដល់ការវិភាគលម្អិតទៅលើលទ្ធផលដែលទទួលបាន។ ការវិភាគនេះបានបង្ហាញនូវទិន្នន័យដ៏គួរឱ្យចាប់អារម្មណ៍ និងជារបកគំហើញថ្មី ដែលឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពគម្រោង ព្រមទាំងផ្តល់មូលដ្ឋានដ៏រឹងមាំសម្រាប់សកម្មភាព និងសេចក្តីសម្រេចចិត្តនាពេលអនាគតផងដែរ។

ក្នុងអំឡុងដំណើរការវិភាគនេះ យើងបានរកឃើញទាំងចំណុចខ្លាំង និងឱកាសដើម្បីធ្វើការកែលម្អ។ មានការគូសបញ្ជាក់ពីជោគជ័យដែលសម្រេចបានមកដល់ពេលបច្ចុប្បន្ន ក៏ដូចជាបញ្ហាប្រឈម និងឧបសគ្គនានាដែលចាំបាច់ត្រូវធ្វើការដោះស្រាយនៅក្នុងដំណាក់កាលបន្ទាប់នៃគម្រោងនេះ។ ជារួម វឌ្ឍនភាពដែលសម្រេចបានមកដល់បច្ចុប្បន្ននេះ គឺជាសក្ខីភាពបញ្ជាក់ពីការប្តេជ្ញាចិត្ត ការលះបង់ និងសមត្ថភាពរបស់ក្រុមការងារក្នុងការតទល់នឹងបញ្ហាប្រឈម និងជម្នះបញ្ហាលំបាក ឆ្ពោះទៅរកការសម្រេចបាននូវគោលដៅរួមរបស់គម្រោង។

ឆ្ពោះទៅមុខ ក្រុមការងារប្តេជ្ញាចិត្តបន្តបំពេញការងារដោយស្មារតីសហការ និងផ្តោតការយកចិត្តទុកដាក់ឆ្ពោះទៅរកការសម្រេចឱ្យបាននូវគោលបំណងរបស់គម្រោង។ សកម្មភាព និងយុទ្ធសាស្រ្តថ្មីបានរៀបចំឡើង ដើម្បីដោះស្រាយបញ្ហាប្រឈមដែលនឹងកើតឡើង និងបង្កើនឥទ្ធិពលវិជ្ជមានរបស់គម្រោងនៅក្នុងផ្នែកពាក់ព័ន្ធទាំងអស់ឱ្យដល់កម្រិតអតិបរិមា។ ជាចុងក្រោយ ជោគជ័យនៃគម្រោងនេះ ត្រូវពឹងផ្អែកទៅលើកិច្ចខិតខំប្រឹងប្រែង និងការតាំងចិត្តរួមគ្នារបស់ក្រុមការងារក្នុងការសម្រេចឱ្យបាននូវលទ្ធផលដ៏ល្អបំផុត និងយូរអង្វែង។

ខាងក្រោមនេះ គឺជាឧទាហរណ៍តំណាងមួយចំនួនអំពីលទ្ធផលដែលទទួលបានតាមរយៈការស្ទង់មតិ។ ឧទាហរណ៍ទាំងនេះផ្តល់នូវទិដ្ឋភាពទូទៅអំពីការយល់ឃើញ និងមតិយោបល់ដែលប្រមូលបានក្នុងអំឡុងដំណើរការស្រាវជ្រាវ ដែលគ្របដណ្តប់លើប្រធានបទពាក់ព័ន្ធជាច្រើន ព្រមទាំងផ្តល់នូវព័ត៌មានដ៏មានតម្លៃអំពីទិដ្ឋភាពខុសៗគ្នានៃប្រធានបទដែលលើកយកមកសិក្សា។




*រូបភាព 12៖ ការតំណាងយេនឌ័រពីប្រទេសឡាវ កម្ពុជា និងម៉ាឡេស៊ី*




*រូបភាព 13៖ ការតំណាងយេនឌ័រពីប្រទេសកម្ពុជា*




*រូបភាព 14៖ ការតំណាងយេនឌ័រពីប្រទេសឡាវ*




*រូបភាព 15៖ ការតំណាងយេនឌ័រពីប្រទេសម៉ាឡេស៊ី*

ជាការចាំបាច់ណាស់ដែលត្រូវរួមបញ្ចូលយេនឌ័រជាអថេរមួយនៅក្នុងការស្ទង់មតិ ក្នុងគោលបំណងពន្លឿនការធ្វើបរិវត្តកម្មឌីជីថលសម្រាប់ឧត្តមសិក្សានៅប្រទេសម៉ាឡេស៊ី កម្ពុជា និងឡាវនៅតំបន់អាស៊ីអាគ្នេយ៍។ ការស្ទង់មតិនេះជួយឱ្យយើងដឹងអំពីភាពខុសគ្នា និងភាពស្រដៀងគ្នានៃលទ្ធភាព ការចូលរួម និងលទ្ធផលអប់រំរវាងបុរស និងស្ត្រីនៅក្នុងបរិបទនៃបរិវត្តកម្មឌីជីថល។ តាមរយៈការប្រមូលទិន្នន័យបែងចែកតាមយេនឌ័រយើងអាចរកឃើញ និងដោះស្រាយគម្លាតយេនឌ័រនៅក្នុងលទ្ធភាពចូលប្រើប្រាស់បច្ចេកវិទ្យា ការចូលរួមនៅក្នុងសកម្មភាពឌីជីថល និងឱកាសសិក្សាតាមប្រព័ន្ធអនឡាញបាន។ ចំណុចនេះមានសារៈសំខាន់ណាស់ក្នុងការធានាធ្វើយ៉ាងណាឱ្យគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលមានបរិយាប័ន្ន និងសមធម៌ ព្រមទាំងធានាថាអាចផ្តល់ផលប្រយោជន៍ដល់អ្នកសិក្សាទាំងអស់ដោយមិនគិតអំពីយេនឌ័រ។

ការស្ទង់មតិនិស្សិត និងបុគ្គលិកសាកលវិទ្យាល័យនៅប្រទេសកម្ពុជា ឡាវ និងម៉ាឡេស៊ី គឺជាឧបករណ៍ដ៏មានតម្លៃមួយដើម្បីស្វែងយល់អំពីភាពស្មុគស្មាញ និងតម្រូវការនៅក្នុងគ្រឹះស្ថានអប់រំទាំងនេះ។ ការស្ទង់មតិនេះធ្វើឱ្យមានការស្វែងយល់ស៊ីជម្រៅអំពីមតិយោបល់ដាច់ដោយឡែក និងមតិយោបល់រួម ដែលផ្តល់នូវការយល់ឃើញគ្រប់ជ្រុងជ្រោយអំពីក្តីបារម្ភ បំណងប្រាថ្នា និងសំណូមពររបស់អ្នកដែលពាក់ព័ន្ធដោយផ្ទាល់នៅក្នុងបរិយាកាសសាកលវិទ្យាល័យ។

ទីមួយ ការស្ទង់មតិទាំងនេះផ្តល់នូវថ្នាលមួយដែលនិស្សិត និងបុគ្គលិកម្នាក់ៗ អាចបង្ហាញអំពីទស្សនៈរបស់ពួកគេដោយអនាមិក និងមិនភ័យខ្លាចរងការផ្ចាញ់ផ្ចាលឡើយ។ ការស្ទង់មតិបែបនេះ លើកទឹកចិត្តឱ្យមានការប្រាស្រ័យទាក់ទងបើកចំហ និងស្មោះត្រង់ ដែលជាលទ្ធផលជួយសម្របសម្រួលដល់ការកំណត់រកបញ្ហាដែលអាចនឹងត្រូវបានមើលរំលង។ បន្ថែមពីនេះ

តាមរយៈការប្រមូលទិន្នន័យពីមនុស្សជាច្រើន យើងទទួលបាននូវការអះអាងអំពីមតិយោបល់ និងបទពិសោធន៍កាន់តែពេញលេញនៅក្នុងគ្រឹះស្ថានសាកលវិទ្យាល័យ ដែលជំរុញឱ្យមានការយល់ដឹងកាន់តែសុក្រឹតអំពីតម្រូវការ និងបំណងប្រាថ្នាខុសៗគ្នា។

តាមរយៈការវិភាគទិន្នន័យដែលប្រមូលបាន យើងអាចកំណត់រកលំនាំ និងនិន្នាការសំខាន់ៗនៃមតិយោបល់ និងក្តីបារម្ភដែលបានបង្ហាញ។ ឧទាហរណ៍ យើងអាចរកឃើញថានិស្សិតជាច្រើននៅក្នុងកម្មវិធីសិក្សានីមួយៗ មានការមិនពេញចិត្តចំពោះធនធានគាំទ្រដែលផ្តល់ជូន ស្របពេលដែលបុគ្គលិកផ្នែករដ្ឋបាលអាចនឹងមានក្តីបារម្ភអំពីបន្ទុកការងារ និងប្រសិទ្ធភាពនៃដំណើរការផ្ទៃក្នុង។ លំនាំទាំងនេះផ្តល់នូវព័ត៌មានដ៏មានតម្លៃអំពីផ្នែកដែលមានបញ្ហា ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាអាទិភាព។

លើសពីនេះទៅទៀត ការស្ទង់មតិក៏អាចជួយកំណត់អាទិភាពតម្រូវការដែលបានកំណត់រកឃើញផងដែរ។ តាមរយៈការយល់ដឹងអំពីទំហំ និងភាពបន្ទាន់នៃក្តីបារម្ភខុសៗគ្នានេះ អ្នកមានសិទ្ធិអំណាច និងអ្នកធ្វើសេចក្តីសម្រេចចិត្តនៅសាកលវិទ្យាល័យ អាចធ្វើការបែងចែកធនធានឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាដែលសំខាន់បំផុត។ ការធ្វើបែបនេះគឺដើម្បីធានាថាបានអនុវត្តវិធានការកែតម្រូវបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ដើម្បីបង្កើនឥទ្ធិពលវិជ្ជមានលើគ្រឹះស្ថានសាកលវិទ្យាល័យឱ្យដល់កម្រិតអតិបរិមា។

លទ្ធផលនៃការស្ទង់មតិនេះ ក៏ជាប្រភពព័ត៌មានដ៏មានតម្លៃមួយផងដែរសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងស្ថាប័ន។ ទិន្នន័យដែលប្រមូលបាន អាចផ្តល់ជាព័ត៌មានដល់ការបង្កើតគោលនយោបាយ ការរៀបចំផែនការជាយុទ្ធសាស្ត្រ និងការអនុវត្តគំនិតផ្តួចផ្តើមជាក់លាក់ដែលរៀបចំឡើងដើម្បីលើកកម្ពស់គុណភាពរបស់សិស្ស និងបទពិសោធន៍ការងារនៅក្នុងសាកលវិទ្យាល័យផងដែរ។ ចាប់ពីការបែងចែកថវិកា ដល់ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ រហូតដល់ការអនុវត្តកម្មវិធីគាំទ្រនិស្សិត ការសម្រេចចិត្តនានាដែលផ្អែកលើទិន្នន័យដែលទុកចិត្តបាន មានសក្តានុពលក្នុងការបង្កើតបាននូវការផ្លាស់ប្តូរដ៏ធំធេង និងជាវិជ្ជមាននៅទូទាំងគ្រឹះស្ថានសាកលវិទ្យាល័យ។

ជារួម ការស្ទង់មតិនិស្សិត និងបុគ្គលិកសាកលវិទ្យាល័យនៅប្រទេសកម្ពុជា ឡាវ និងម៉ាឡេស៊ី ផ្តល់នូវការយល់ដឹងដ៏មានតម្លៃអំពីអំពីភាពស្មុគស្មាញ និងតម្រូវការនៅក្នុងគ្រឹះស្ថានអប់រំទាំងនេះ។ តាមរយៈការទាញយកព័ត៌មាននេះមកប្រើប្រាស់ឱ្យមានប្រសិទ្ធភាព គេអាចដោះស្រាយក្តីបារម្ភដែលកំពុងមាន ធ្វើឱ្យបទពិសោធន៍នៅសាកលវិទ្យាល័យប្រសើរឡើង និងលើកកម្ពស់បរិយាកាសនៅសាកលវិទ្យាល័យឱ្យកាន់តែវិជ្ជមាន និងសម្បូរបែបសម្រាប់អ្នកពាក់ព័ន្ធទាំងអស់។

## 9.1 ប្រទេសឡាវ

នៅប្រទេសឡាវ សាកលវិទ្យាល័យជាតិឡាវ (NUOL) និងសាកលវិទ្យាល័យ Savannakhet University (SKU) បានក្លាយជាសាលាវិទ្យាល័យឈានមុខគេក្នុងការជំរុញយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលប្រកបដោយភាពច្នៃប្រឌិតនៅក្នុងការអប់រំកម្រិតឧត្តមសិក្សា។ តាមរយៈកិច្ចសហការជាយុទ្ធសាស្ត្រជាមួយក្រុមហ៊ុនបច្ចេកវិទ្យា និងការប្តេជ្ញាចិត្តដ៏មោះមុតក្នុងការទាញយកប្រយោជន៍ពីបច្ចេកវិទ្យាទំនើប គ្រឹះស្ថានអប់រំទាំងពីរនេះបានធ្វើបរិវត្តកម្មការបង្រៀន ការសិក្សា និងការអនុវត្តរដ្ឋបាល ដើម្បីបំពេញតាមតម្រូវការប្រែប្រួលឥតឈប់ឈររបស់សហគមន៍អប់រំរបស់ពួកគេ។

សាកលវិទ្យាល័យជាតិឡាវ ក្នុងនាមជាគ្រឹះស្ថានអប់រំឧត្តមសិក្សាល្អវិសេសជាងគេនៅក្នុងប្រទេសឡាវ បាន និងកំពុងជាកម្លាំងចលករឈានមុខគេនៃគំនិតផ្តួចផ្តើមអប់រំឌីជីថល។ គំនិតផ្តួចផ្តើមមួយក្នុងចំណោមគំនិតផ្តួចផ្តើមសំខាន់របស់គ្រឹះស្ថានអប់រំនេះ គឺជាការរួមបញ្ចូលការអប់រំដែលពង្រឹងដោយបច្ចេកវិទ្យា ដែលឧបករណ៍ និងថ្នាលឌីជីថល គឺត្រូវបានបញ្ចូលទៅក្នុងការបង្រៀនក្នុងថ្នាក់យ៉ាងរលូន ដើម្បីពង្រឹងការចូលរួមរបស់សិស្ស និងបណ្តុះនូវស្មារតីសិក្សារៀនសូត្រសកម្ម។ តាមរយៈការរួមបញ្ចូលធនធានពហុមេឌៀ លំហាត់ត្រាប់អន្តរកម្ម និងមន្ទីរពិសោធន៍សិប្បនិម្មិត សាកលវិទ្យាល័យជាតិឡាវ បានបង្កើតនូវបទពិសោធន៍សិក្សារៀនសូត្រដែលបង្កលក្ខណៈងាយស្រួលដល់ការចូលរួមរបស់និស្សិត ដែលត្រូវបានរៀបចំឡើងសម្របតាមរបៀប និងចំណង់ចំណូលចិត្តសិក្សារៀនសូត្រ។ លើសពីនេះ សាកលវិទ្យាល័យជាតិឡាវបានសហការជាដៃគូជាមួយនឹងក្រុមហ៊ុនបច្ចេកវិទ្យាឈានមុខគេ ដើម្បីរៀបចំបង្កើតកម្មវិធីអភិវឌ្ឍន៍ជំនាញឌីជីថល ដែលនឹងបំពាក់បំប៉ននិស្សិតនូវជំនាញបច្ចេកទេសដែលសំខាន់សម្រាប់ភាពជោគជ័យនៅក្នុងសេដ្ឋកិច្ចឌីជីថល។ តាមរយៈសិក្ខាសាលា កម្មវិធីហាត់ការ និងកម្មវិធីផ្តល់វិញ្ញាបនបត្រដែលឧបត្ថម្ភដោយវិស័យនេះ សាកលវិទ្យាល័យជាតិឡាវធានាថានិស្សិតដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យរបស់ខ្លួនទៅ គឺត្រៀមខ្លួនបានយ៉ាងល្អប្រសើរនៅក្នុងការអភិវឌ្ឍខ្លួននៅក្នុងទីផ្សារការងារដែលមានការវិវត្តយ៉ាងឆាប់រហ័សនេះ។

ស្រដៀងគ្នានេះដែរ សាកលវិទ្យាល័យ Savannakhet University បានចាប់យកនូវបរិវត្តកម្មឌីជីថល ដើម្បីពង្រឹងការបង្រៀន ការសិក្សា និងដំណើរការរដ្ឋបាលរបស់ខ្លួន។ តាមរយៈការចងសម្ព័ន្ធជាយុទ្ធសាស្ត្រជាមួយដៃគូផ្នែកបច្ចេកវិទ្យា សាកលវិទ្យាល័យ SKU បានអនុវត្តគំនិតផ្តួចផ្តើមសិក្សាបែបឌីជីថលប្រកបដោយលក្ខណៈច្នៃប្រឌិត ក្នុងគោលបំណងធ្វើឱ្យបទពិសោធន៍របស់និស្សិតកាន់តែសម្បូរបែប និងត្រៀមរៀបចំនិស្សិតសម្រាប់ឱកាសនាពេល

អនាគត។ តាមរយៈការទាញយកប្រយោជន៍ពីបច្ចេកវិទ្យាទំនើប សាកលវិទ្យាល័យ SKU បាន ដាក់ឱ្យដំណើរការថ្នាក់រៀនតាមប្រព័ន្ធអ៊ីនធឺណិត ថ្នាលសិក្សាតាមប្រព័ន្ធអ៊ីនធឺណិតលក្ខណៈ អន្តរកម្ម និងបណ្ណាល័យឌីជីថល ដើម្បីពង្រីកលទ្ធភាពទទួលបានការអប់រំដែលមានគុណភាព។ លើសពីនេះ សាកលវិទ្យាល័យ SKU ប្រើប្រាស់ប្រព័ន្ធវិភាគទិន្នន័យខ្នាតធំ ដើម្បីពង្រឹងការ គ្រប់គ្រងការអប់រំ និងសេវាគាំទ្រនិស្សិត ដែលជំរុញឱ្យមានការរៀបចំបទពិសោធន៍សិក្សាតាម តម្រូវការ និងការអន្តរាគមន៍ចំគោលដៅក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់និស្សិត។

កិច្ចខិតខំប្រឹងប្រែងត្រួសត្រាយផ្លូវទាំងនេះរបស់សាកលវិទ្យាល័យជាតិឡាវ និងសាកលវិទ្យាល័យ SKU បានបង្ហាញពីជំហររបស់សាកលវិទ្យាល័យទាំងពីរនេះជាអ្នកត្រួសត្រាយផ្លូវនៅក្នុងការ អប់រំឌីជីថលនៅក្នុងប្រទេសឡាវ ដែលកំណត់សាកលវិទ្យាល័យទាំងពីរនេះជាសាកលវិទ្យាល័យ នាំមុខគេនៅក្នុងការទាញយកប្រយោជន៍ពីបច្ចេកវិទ្យា ដើម្បីធ្វើបរិវត្តកម្មវិស័យអប់រំឧត្តម សិក្សា។ តាមរយៈការចាប់យកនវានុវត្តន៍ឌីជីថល និងការបណ្តុះភាពជាដៃគូយុទ្ធសាស្ត្រ គ្រឹះស្ថានអប់រំទាំងពីរនេះបន្តធ្វើឱ្យឧត្តមភាពអប់រំកាន់តែរីកចម្រើនទៅមុខ ដែលពង្រឹងសមត្ថភាព និស្សិតឱ្យរីកចម្រើននៅក្នុងយុគសម័យឌីជីថល និងរួមចំណែកយ៉ាងមានអត្ថន័យនៅក្នុងការ អភិវឌ្ឍរបស់ប្រទេសឡាវ។

## 9.2 ប្រទេសកម្ពុជា

នៅកម្ពុជា វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) និងសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ (UHS) បានក្លាយជាសាកលវិទ្យាល័យឈានមុខគេ ក្នុងការជំរុញយុទ្ធសាស្ត្របរិវត្តកម្មឌីជីថល សម្រាប់ការអប់រំឧត្តមសិក្សាប្រកបដោយភាពច្នៃប្រឌិត។ តាមរយៈកិច្ចសហការជាយុទ្ធសាស្ត្រ ជាមួយក្រុមហ៊ុនបច្ចេកវិទ្យា និងការប្តេជ្ញាចិត្តដ៏មោះមុតក្នុងការទាញយកប្រយោជន៍ពីបច្ចេក វិទ្យាទំនើប គ្រឹះស្ថានអប់រំទាំងពីរនេះបានធ្វើបរិវត្តកម្មការបង្រៀន ការសិក្សា និងការអនុវត្ត រដ្ឋបាល ដើម្បីបំពេញតាមតម្រូវការប្រែប្រួលឥតឈប់ឈររបស់សហគមន៍អប់រំរបស់ខ្លួន។

គំនិតផ្តួចផ្តើមដ៏សំខាន់មួយរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា គឺជាការផ្តោតការយកចិត្តទុកដាក់ លើការអប់រំពង្រឹងដោយបច្ចេកវិទ្យា ដែលឧបករណ៍ និងថ្នាលឌីជីថល គឺត្រូវបានបញ្ចូលទៅ ក្នុងការបង្រៀនក្នុងថ្នាក់យ៉ាងរលូន ដើម្បីពង្រឹងការចូលរួមរបស់សិស្ស និងបណ្តុះនូវស្មារតី សិក្សារៀនសូត្រសកម្ម។ តាមរយៈការរួមបញ្ចូលធនធានពហុមេឌៀ លំហាត់គ្រាប់អន្តរកម្ម និង មន្ទីរពិសោធន៍សិប្បនិម្មិត វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានបង្កើតនូវបទពិសោធន៍សិក្សារៀន សូត្រដែលបង្កលក្ខណៈងាយស្រួលដល់ការចូលរួមរបស់និស្សិត ដែលត្រូវបានរៀបចំឡើង

ស្របតាមរបៀប និងចំណង់ចំណូលចិត្តសិក្សារៀនសូត្រ។ លើសពីនេះ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាបានសហការជាដៃគូជាមួយនឹងក្រុមហ៊ុនបច្ចេកវិទ្យាឈានមុខគេ ដើម្បីរៀបចំបង្កើតកម្មវិធីអភិវឌ្ឍន៍ជំនាញឌីជីថល ដែលនឹងបំពាក់បំប៉ននិស្សិតនូវជំនាញបច្ចេកទេសដែលសំខាន់ចាំបាច់ ដើម្បីភាពជោគជ័យនៅក្នុងសេដ្ឋកិច្ចឌីជីថល។ តាមរយៈសិក្ខាសាលា កម្មវិធីហាត់ការ និងកម្មវិធីផ្តល់វិញ្ញាបនបត្រដែលឧបត្ថម្ភដោយវិស័យនេះ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាធានាថានិស្សិតដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យរបស់ខ្លួនទៅ បានត្រៀមខ្លួនបានយ៉ាងល្អប្រសើរនៅក្នុងការអភិវឌ្ឍខ្លួននៅក្នុងទីផ្សារការងារដែលមានការវិវត្តយ៉ាងឆាប់រហ័សនេះ។

ស្រដៀងគ្នានេះដែរ សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ បានចាប់យកនូវបរិវត្តកម្មឌីជីថលដើម្បីពង្រឹងការបង្រៀន ការសិក្សា និងដំណើរការរដ្ឋបាល។ តាមរយៈការចងសម្ព័ន្ធជាយុទ្ធសាស្ត្រជាមួយដៃគូផ្នែកបច្ចេកវិទ្យា សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ បានចាប់យកគំនិតផ្តួចផ្តើមសិក្សាបែបឌីជីថលប្រកបដោយលក្ខណៈច្នៃប្រឌិត ក្នុងគោលបំណងធ្វើឱ្យបទពិសោធន៍របស់និស្សិតកាន់តែសម្បូរបែប និងត្រៀមរៀបចំនិស្សិតសម្រាប់ឱកាសនាពេលអនាគត។ តាមរយៈការទាញយកប្រយោជន៍ពីបច្ចេកវិទ្យាទំនើប សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ បានដាក់ឱ្យដំណើរការថ្នាក់រៀនតាមប្រព័ន្ធអ៊ីនធឺណិត ថ្នាលសិក្សាតាមប្រព័ន្ធអ៊ីនធឺណិតលក្ខណៈអន្តរកម្ម និងបណ្ណាល័យឌីជីថល ដើម្បីពង្រីកលទ្ធភាពទទួលបានការអប់រំដែលមានគុណភាព។ លើសពីនេះ សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ ប្រើប្រាស់ប្រព័ន្ធវិភាគទិន្នន័យខ្នាតធំ ដើម្បីពង្រឹងការគ្រប់គ្រងការអប់រំ និងសេវាគាំទ្រនិស្សិត ដែលជំរុញឱ្យមានការរៀបចំបទពិសោធន៍សិក្សាតាមតម្រូវការ និងការអន្តរាគមន៍ចំគោលដៅក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់និស្សិត។

កិច្ចខិតខំប្រឹងប្រែងត្រួសត្រាយផ្លូវទាំងនេះ ដែលអនុវត្តដោយ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និង សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ បានបង្ហាញជំហររបស់សាកលវិទ្យាល័យទាំងពីរនេះជាអ្នកត្រួសត្រាយផ្លូវនៅក្នុងការអប់រំឌីជីថលនៅក្នុងប្រទេសកម្ពុជា ដែលកំណត់សាកលវិទ្យាល័យទាំងពីរនេះជាសាកលវិទ្យាល័យនាំមុខគេនៅក្នុងការទាញយកប្រយោជន៍ពីបច្ចេកវិទ្យា ដើម្បីធ្វើបរិវត្តកម្មវិស័យអប់រំឧត្តមសិក្សា។ តាមរយៈការអនុវត្តនវានុវត្តន៍ឌីជីថល និងការបណ្តុះភាពជាដៃគូយុទ្ធសាស្ត្រ គ្រឹះស្ថានអប់រំទាំងពីរនេះបន្តធ្វើឱ្យឧត្តមភាពអប់រំកាន់តែរីកចម្រើនទៅមុខ ដែលពង្រឹងសមត្ថភាពនិស្សិតឱ្យរីកចម្រើននៅក្នុងយុគសម័យឌីជីថល និងរួមចំណែកយ៉ាងមានអត្ថន័យនៅក្នុងការអភិវឌ្ឍសង្គម។

## 9.3 ប្រទេសម៉ាឡេស៊ី

សាកលវិទ្យាល័យបច្ចេកវិទ្យាម៉ាឡេស៊ី (UTM) និងសាកលវិទ្យាល័យ University Malaysia Sabah (UMS) បានកសាងខ្លួនជាអ្នកត្រួសត្រាយផ្លូវនៅក្នុងការដាក់បញ្ចូលបច្ចេកវិទ្យាឌីជីថលនៅក្នុងការអប់រំឧត្តមសិក្សានៅប្រទេសម៉ាឡេស៊ី ដែលជាអ្នកនាំមុខគេក្នុងគំនិតផ្តួចផ្តើមប្រកបដោយភាពច្នៃប្រឌិតដើម្បីពង្រឹងការបង្រៀន ការសិក្សា និងសមត្ថភាពស្រាវជ្រាវ។ នៅជួរមុខនៃកិច្ចខិតខំប្រឹងប្រែងធ្វើបរិវត្តកម្មឌីជីថលរបស់សាកលវិទ្យាល័យបច្ចេកវិទ្យាម៉ាឡេស៊ី និងសាកលវិទ្យាល័យ UTM គឺជាគំនិតផ្តួចផ្តើមសាលារៀនឆ្លាត ដែលទាញយកប្រយោជន៍ពីបច្ចេកវិទ្យាអ៊ីនធឺណិតនៃវត្ថុ (IoT) បច្ចេកវិទ្យាវិភាគទិន្នន័យ និងបញ្ញាសិប្បនិម្មិត ដើម្បីបង្កើតនូវបរិយាកាសសិក្សាឆ្លាតវៃ និងមានអន្តរទំនាក់ទំនង។ តាមរយៈការដាក់ឱ្យដំណើរការសិនស័រឆ្លាតវៃ ឧបករណ៍ IoT និងប្រព័ន្ធវិភាគទំនើប គំនិតផ្តួចផ្តើមសាលាឆ្លាតវៃរបស់សាកលវិទ្យាល័យ UMS និង UTM ជំរុញឱ្យសាលាអាចធ្វើការតាមដានត្រួតពិនិត្យ និងគ្រប់គ្រងមូលដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ និងធនធានរបស់សាកលវិទ្យាល័យបានភ្លាមៗទាន់ពេលវេលា។ ប្រព័ន្ធទាំងនេះរួមមានថ្នាក់រៀនឆ្លាតវៃ ដែលបំពាក់នូវក្តារខៀនអន្តរកម្ម ឧបករណ៍បញ្ចាំងស្លាយដ៏ឌីជីថល និងឧបករណ៍សិក្សាបែបសហការ ដែលបង្កើនការចូលរួមរបស់និស្សិត និងសម្របសម្រួលបទពិសោធន៍សិក្សាសកម្ម។ លើសពីនេះ សាកលវិទ្យាល័យ UTM និង UMS បានបង្កើតមន្ទីរពិសោធន៍នវានុវត្តន៍ឌីជីថល និងកន្លែងធ្វើការរួមគ្នា (maker spaces) នៅក្នុងបរិវេណសាកលវិទ្យាល័យ ដែលផ្តល់ឱកាសដល់និស្សិតក្នុងការសិក្សាស្វែងយល់អំពីបច្ចេកវិទ្យាថ្មីៗដូចជា ការបោះពុម្ពបីវិមាត្រ (3D) មនុស្សយន្ត (robotics) និងបច្ចេកវិទ្យាពិភពនិម្មិត (virtual reality)។ មជ្ឈមណ្ឌលនវានុវត្តន៍ទាំងនេះ ដើរតួនាទីជាថ្នាលបណ្តុះសម្រាប់ភាពច្នៃប្រឌិត ការពិសោធន៍ និងសហាគ្រិនភាព ដែលពង្រឹងនិស្សិតឱ្យរៀនបង្កើតដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតចំពោះបញ្ហាជាក់ស្តែង និងបណ្តុះនូវវប្បធម៌នវានុវត្តន៍នៅក្នុងសហគមន៍សាកលវិទ្យាល័យ។ លើសពីនេះ សាកលវិទ្យាល័យ UTM និង UMS បានបង្កើតកិច្ចសហការជាយុទ្ធសាស្ត្រជាមួយដៃគូក្នុងវិស័យ ដើម្បីពង្រឹងជំនាញឌីជីថល និងសហគ្រិនភាពក្នុងចំណោមនិស្សិត។ តាមរយៈគម្រោង ការហាត់ការ និងកម្មវិធីហ្វឹកហាត់ដែលឧបត្ថម្ភដោយវិស័យនេះ និស្សិតទទួលបាននូវបទពិសោធន៍ជាក់ស្តែងដ៏មានតម្លៃ ការយល់ដឹងអំពីវិស័យ និងឱកាសបង្កើតបណ្តាញដែលត្រៀមរៀបចំនិស្សិតសម្រាប់អាជីពការងារដែលជោគជ័យនៅក្នុងសេដ្ឋកិច្ចឌីជីថល។ តាមរយៈការប្រកាន់យកនូវនវានុវត្តន៍ឌីជីថល និងការបណ្តុះវប្បធម៌សហគ្រិនភាព សាកលវិទ្យាល័យ UTM និង UMS បានកំណត់ជំហរខ្លួនឯងជាសាកលវិទ្យាល័យឈានមុខគេនៅក្នុងវិស័យអប់រំឌីជីថលនៅក្នុងប្រទេសម៉ាឡេស៊ី។ តាមរយៈគំនិតផ្តួចផ្តើមសាលាឆ្លាតវៃ មន្ទីរពិសោធន៍

នវានុវត្តន៍ឌីជីថល និងកិច្ចសហការជាមួយវិស័យ សាកលវិទ្យាល័យ UTM និង UMS បន្ត ជំរុញវិសាលភាពនៃនវានុវត្តន៍បច្ចេកវិទ្យាឱ្យដល់វិស័យអប់រំឧត្តមសិក្សា ដែលពង្រឹងនិស្សិតឱ្យក្លាយជាអ្នកដឹកនាំ និងអ្នកបង្កើតថ្មីដែលត្រៀមខ្លួនរួចជាស្រេចសម្រាប់អនាគតនៅក្នុងយុគសម័យឌីជីថលនេះ។

នៅប្រទេសឡាវ សាកលវិទ្យាល័យជាតិឡាវ (NUOL) និងសាកលវិទ្យាល័យ Savannakhet University (SKU) បានសម្រេចនូវដំណើរអភិវឌ្ឍន៍គួរឱ្យគត់សម្គាល់ក្នុងការជំរុញយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលប្រកបដោយភាពច្នៃប្រឌិតនៅក្នុងការអប់រំឧត្តមសិក្សា។ សាកលវិទ្យាល័យជាតិឡាវ ក្នុងនាមជាគ្រឹះស្ថានអប់រំឈានមុខគេ បាន និងកំពុងបំពេញការងារយ៉ាងសកម្មនៅក្នុងការរួមបញ្ចូលបច្ចេកវិទ្យាទៅក្នុងការអនុវត្តការបង្រៀន និងការសិក្សា។ ប៉ុន្តែ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងបែបនេះក្តី ក៏អាចនៅមានបញ្ហាប្រឈមនៅក្នុងការសម្រេចឱ្យបាននូវការប្រកាន់យកឱ្យបានទូលំទូលាយ និងប្រកបដោយឯកសណ្ឋានភាពនៅក្នុងការបញ្ចូលបច្ចេកវិទ្យានៅគ្រប់មុខវិជ្ជា និងដេប៉ាតឺម៉ង់ទាំងអស់។ ទោះបីជាមហាវិទ្យាល័យមួយចំនួននៅសាកលវិទ្យាល័យជាតិឡាវ បង្ហាញឱ្យឃើញអំពីការប្រើប្រាស់បច្ចេកវិទ្យាទំនើបក្តី ក៏មានមហាវិទ្យាល័យផ្សេងទៀតអាចនឹងមានការយឺតយ៉ាវ ដោយសារតែកង្វះធនធាន ឬហេដ្ឋារចនាសម្ព័ន្ធឌីជីថលមានកម្រិតខុសគ្នា។ ស្រដៀងគ្នានេះដែរ គំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលរបស់សាកលវិទ្យាល័យ SKU បាន និងកំពុងមានការសាទរផងដែរ ប៉ុន្តែការប្រកាន់យកបច្ចេកវិទ្យាអាចមានភាពមិនស៊ីគ្នាក្នុងចំណោមកម្មវិធីសិក្សាខុសៗគ្នា។ ការដោះស្រាយភាពមិនស៊ីគ្នាទាំងនេះ និងការធានាបាននូវលទ្ធភាពទទួលបានឱកាសសិក្សាជំរុញដោយបច្ចេកវិទ្យា គួរតែជាអាទិភាពសម្រាប់ទាំងសាកលវិទ្យាល័យជាតិឡាវ និងសាកលវិទ្យាល័យ SKU ដើម្បីអាចពង្រីកអត្ថប្រយោជន៍នៃការអប់រំឌីជីថល និងលើកកម្ពស់កំណើនប្រកបដោយបរិយាប័ន្នពិតប្រាកដឱ្យដល់កម្រិតអតិបរិមា។ នៅកម្ពុជា វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) និងសាកលវិទ្យាល័យហេង សំរិន ត្បូងឃ្មុំ (UHS) បានក្លាយជាសាកលវិទ្យាល័យឈានមុខគេក្នុងការជំរុញបរិវត្តកម្មឌីជីថលសម្រាប់ការអប់រំកម្រិតឧត្តមសិក្សា។ ទោះជាយ៉ាងនេះក្តី ខណៈពេលដែលគ្រឹះស្ថានអប់រំទាំងពីរបានធ្វើការអភិវឌ្ឍន៍ដ៏គួរឱ្យកត់សម្គាល់នៅក្នុងការរួមបញ្ចូលបច្ចេកវិទ្យាទៅក្នុងការបង្រៀន ការសិក្សា និងការអនុវត្តរដ្ឋបាលនេះ ក៏អាចមានផ្នែកខ្លះដែលត្រូវការកែលម្អបន្ថែមទៀត ដើម្បីពង្រីកវិសាលភាពការអនុវត្ត និងចីរភាពនៃគំនិតផ្តួចផ្តើមឌីជីថល។ ឧទាហរណ៍ ទោះបីជាការផ្តោតការយកចិត្តទុកដាក់របស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាលើការសិក្សាជំរុញដោយបច្ចេកវិទ្យាទទួលបានការសាទរក្តី ក៏ការធានាក្នុងការពង្រីកគំនិតផ្តួចផ្តើមនេះ និងផ្តល់លទ្ធភាពដល់និស្សិតទាំងអស់ ដោយមិនគិតអំពីប្រវត្តិការសិក្សា ឬជំនាញបច្ចេកវិទ្យារបស់

និស្សិត មានសារៈសំខាន់ខ្លាំងដើម្បីទទួលបានលទ្ធផលអប់រំប្រកបដោយសមធម៌។ ស្រដៀងគ្នានេះដែរ ការប្រកាន់យកបរិវត្តកម្មឌីជីថលរបស់សាកលវិទ្យាល័យ ហោង សំរិន ត្បូងឃ្មុំ គួរតែកំណត់អាទិភាពទៅលើការដោះស្រាយគន្លាតឌីជីថលណាមួយដែលអាចកើតមានក្នុងចំណោមនិស្សិត និងបុគ្គលិកអប់រំ ដោយធានាថាភាគីពាក់ព័ន្ធទាំងអស់មានសិទ្ធិស្មើគ្នាក្នុងការចូលទៅប្រើប្រាស់ធនធានសិក្សាជំរុញដោយបច្ចេកវិទ្យា និងសេវាគាំទ្រនានា។ នៅប្រទេសម៉ាឡេស៊ី សាកលវិទ្យាល័យបច្ចេកវិទ្យាម៉ាឡេស៊ី (UTM) និងសាកលវិទ្យាល័យ University Malaysia Sabah (UMS) បានបង្ហាញភាពជាអ្នកនាំមុខក្នុងការបញ្ចូលបច្ចេកវិទ្យាឌីជីថលទៅក្នុងការអប់រំកម្រិតឧត្តមសិក្សា។ ទោះជាយ៉ាងនេះក្តី ដូចគ្នាទៅនឹងគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលទ្រង់ទ្រាយធំដែរ វាអាចនឹងមានការលំបាកក្នុងការធានាឱ្យបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព និងចីរភាពនៃគំនិតផ្តួចផ្តើមឌីជីថលនៅទូទាំងគ្រឹះស្ថានអប់រំទាំងមូល។ ស្របពេលដែលសាកលវិទ្យាល័យ UTM និង UMS បានធ្វើការវិនិយោគយ៉ាងច្រើនលើគំនិតផ្តួចផ្តើមសាលាឆ្លាតវៃ និងមន្ទីរពិសោធន៍នវានុវត្តន៍ឌីជីថល ការវាយតម្លៃ និងការកែលម្អជាបន្តបន្ទាប់លើគំនិតផ្តួចផ្តើមទាំងនេះ គឺមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយបញ្ហាប្រឈមណាមួយដែលកើតមានឡើង និងទាញយកប្រយោជន៍ពីឱកាសថ្មីៗនៅក្នុងវិស័យឌីជីថលដែលមានការវិវត្តន៍យ៉ាងឆាប់រហ័សនេះ។ លើសពីនេះទៅទៀត គ្រឹះស្ថានអប់រំទាំងពីរគួរតែបន្តផ្តោតការយកចិត្តទុកដាក់លើការបណ្តុះវប្បធម៌នវានុវត្តន៍ និងសហគ្រិនភាពឌីជីថលក្នុងចំណោមនិស្សិត និងមហាវិទ្យាល័យ ដើម្បីជំរុញឱ្យមានការរីកចម្រើនប្រកប ដោយចីរភាព និងពេញលេញនៅក្នុងយុគសម័យឌីជីថលនេះ។

## 9.1 គម្លាតបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសនីមួយៗ

### 9.1.1 ប្រទេសឡាវ

សាកលវិទ្យាល័យជាតិឡាវ (NOL) សាកលវិទ្យាល័យ Savannakhet University (SKU) មានភាពលេចធ្លោក្នុងនាមជាសាកលវិទ្យាល័យឈានមុខគេ នៅក្នុងការធ្វើបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសឡាវ ដោយមាននូវថ្នាក់រៀនឌីជីថលទំនើប ថ្នាលសិក្សាតាមប្រព័ន្ធអនឡាញ និងវិធីសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការរួមបញ្ចូលបច្ចេកវិទ្យាទៅក្នុងការបង្រៀន និងការសិក្សា។ ប៉ុន្តែ ជោគជ័យរបស់សាកលវិទ្យាល័យ SKU និង NOL ក៏បានគូសបញ្ជាក់ឱ្យឃើញអំពីគម្លាតបរិវត្តកម្មឌីជីថលយ៉ាងខ្លាំង នៅពេលធ្វើការប្រៀបធៀបជាមួយនឹងបណ្តាសាកលវិទ្យាល័យផ្សេងៗទៀតនៅក្នុងប្រទេសឡាវ ដែលអាចជួបប្រទះនឹងបញ្ហាប្រឈមដូចជា ធនធាន ហេដ្ឋារចនាសម្ព័ន្ធ

ឬជំនាញមានកម្រិតលើផ្នែកបច្ចេកវិទ្យាឌីជីថល។ ទោះបីជាសាកលវិទ្យាល័យ SKU និង NOL មានលទ្ធភាពវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដ៏ទំនើប និងផ្តល់ការបណ្តុះបណ្តាលទូលំទូលាយដល់សាស្ត្រាចារ្យ និងបុគ្គលិកអំពីសមាហរណកម្មបច្ចេកវិទ្យាក៏ដោយ ក៏បណ្តាសាកលវិទ្យាល័យផ្សេងៗទៀតជាច្រើននៅក្នុងប្រទេសឡាវជួបប្រទះការលំបាកក្នុងការតាមឱ្យទាន់ដំណើរវិវត្តន៍នេះ ដោយសារតែកង្វះធនធាន។ សាកលវិទ្យាល័យទាំងនេះជារឿយៗខ្វះខាតនូវធនធានហិរញ្ញវត្ថុក្នុងការវិនិយោគលើបច្ចេកវិទ្យាទំនើប ដំឡើងសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធ ឬផ្តល់ការបណ្តុះបណ្តាលឱ្យបានគ្រប់គ្រាន់ដល់សាស្ត្រាចារ្យ និងបុគ្គលិក។ លើសពីនេះទៅទៀត លទ្ធភាពតភ្ជាប់ទៅនឹងអ៊ីនធឺណិតល្បឿនលឿននិងឧបករណ៍ឌីជីថលនៅមានកម្រិតបន្តធ្វើឱ្យមានគម្លាតឌីជីថលកាន់តែខ្លាំង ដែលរារាំងដល់សមត្ថភាពរបស់និស្សិតក្នុងការចូលរួមឱ្យបានពេញលេញនៅក្នុងបទពិសោធន៍សិក្សាឌីជីថល។ កត្តារួមចំណែកដល់ភាពមិនស៊ីគ្នានេះមានជាច្រើនទិដ្ឋភាព រួមទាំងមូលនិធិរដ្ឋាភិបាលមានកម្រិតសម្រាប់ការអប់រំឧត្តមសិក្សា កង្វះអ្នកជំនាញផ្នែកបច្ចេកវិទ្យាព័ត៌មានដែលមានជំនាញ និងកង្វះការយល់ដឹងអំពីសារៈសំខាន់នៃបរិវត្តកម្មឌីជីថលក្នុងចំណោមថ្នាក់ដឹកនាំសាកលវិទ្យាល័យ។ ជាលទ្ធផល សាកលវិទ្យាល័យទាំងនេះអាចមានការលំបាកក្នុងការរក្សាគុណភាព និងលទ្ធភាពក្នុងការទទួលបានការអប់រំដែលនាំឱ្យមានភាពមិនស៊ីគ្នាលើលទ្ធផលសិក្សា និងឱកាសរបស់និស្សិត។




*រូបភាព 16៖ គម្លាតបរិវត្តកម្មឌីជីថលនៅប្រទេសឡាវ*

ការដោះស្រាយគម្លាតបរិវត្តកម្មឌីជីថលរវាងសាកលវិទ្យាល័យ SKU និង NOL និងបណ្ដាសាកលវិទ្យាល័យផ្សេងៗទៀតនៅក្នុងប្រទេសឡាវ ទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងពីស្ថាប័នរដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងដៃគូវិស័យឯកជន។ កិច្ចខិតខំប្រឹងប្រែងនេះអាចរួមមានការផ្តល់មូលនិធិ និងការគាំទ្រចំគោលដៅសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការផ្តល់កម្មវិធីកសាងសមត្ថភាព និងជំនួយបច្ចេកទេសដល់សាស្ត្រាចារ្យ និងបុគ្គលិក ព្រមទាំងការបណ្តុះឱ្យមានកិច្ចសហការ និងចែករំលែកចំណេះដឹងក្នុងចំណោមសាកលវិទ្យាល័យនានា ដើម្បីប្រើប្រាស់ធនធាន និងជំនាញឱ្យមានប្រសិទ្ធភាព។ តាមរយៈការការផ្តោតអាទិភាពលើគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថល និងការធានាឱ្យបាននូវសិទ្ធិស្មើគ្នាក្នុងការទទួលបានបច្ចេកវិទ្យា និងឱកាសបណ្តុះបណ្តាលប្រទេសឡាវអាចធ្វើការឆ្ពោះទៅរកការលុបបំបាត់គម្លាតនេះ និងលើកកម្ពស់ការអប់រំប្រកបដោយបរិយាប័ន្ន និងគុណភាពខ្ពស់សម្រាប់និស្សិតគ្រប់រូប។




*រូបភាព 17៖ ការដោះស្រាយគម្លាតបរិវត្តកម្មឌីជីថលនៅប្រទេសឡាវ*

### 9.2.2 ប្រទេសកម្ពុជា

នៅកម្ពុជា ទិដ្ឋភាពបរិវត្តកម្មឌីជីថលសម្រាប់ការអប់រំឧត្តមសិក្សាមានភាពខុសគ្នាយ៉ាងខ្លាំងក្នុងចំណោមសាកលវិទ្យាល័យនានា ដោយគ្រឹះស្ថានអប់រំខ្លះឈានមុខគេនៅក្នុងការប្រកាន់យកបច្ចេកវិទ្យា និងការអនុវត្តឌីជីថលប្រកបដោយភាពច្នៃប្រឌិត ស្របពេលដែលសាកលវិទ្យាល័យ

ខ្លះទៀតនៅមានការខ្វះខាតនៅឡើយ។ សាកលវិទ្យាល័យឈានមុខគេលើផ្នែកបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសកម្ពុជា សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងការដំឡើងសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការផ្តល់ការបណ្តុះបណ្តាលដល់សាស្ត្រាចារ្យ និងការពង្រឹងលទ្ធភាពរបស់និស្សិតក្នុងការចូលប្រើប្រាស់ធនធានឌីជីថល។ សាកលវិទ្យាល័យឈានមុខគេនេះ អាចនឹងវិនិយោគលើការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធសាកលវិទ្យាល័យរបស់ខ្លួន ដោយអនុវត្តថ្នាក់រៀនឌីជីថលទំនើប និងការអភិវឌ្ឍផ្លាលសិក្សាតាមប្រព័ន្ធអនឡាញយ៉ាងរឹងមាំ ដើម្បីជួយគាំទ្រដល់ការសិក្សា និងការសហការពីចម្ងាយ។ លើសពីនេះទៅទៀត សាកលវិទ្យាល័យនេះអាចមានការសហការជាមួយអ្នកឈានមុខគេនៅក្នុងវិស័យ និងក្រុមហ៊ុនបច្ចេកវិទ្យា ដើម្បីផ្តល់ជូននិស្សិតនូវបទពិសោធន៍ផ្ទាល់ជាក់ស្តែង និងអាចមានឱកាសប្រើប្រាស់បច្ចេកវិទ្យាទំនើបៗ។




*រូបភាព 18៖ គម្លាតបរិវត្តកម្មឌីជីថលនៅប្រទេសឡាវ*

ផ្ទុយមកវិញ សាកលវិទ្យាល័យកម្ពុជាផ្សេងៗទៀត អាចជួបប្រទះនឹងបញ្ហាប្រឈមដូចជាហេដ្ឋារចនាសម្ព័ន្ធហួសសម័យ ថវិកាសម្រាប់ការដំឡើងសមត្ថភាពបច្ចេកវិទ្យាមានកម្រិត និងកង្វះបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាល ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមឌីជីថល។ សាកលវិទ្យាល័យទាំងនេះ អាចមានការលំបាកក្នុងការផ្តល់ការបណ្តុះបណ្តាល និងធនធានដល់សាស្ត្រាចារ្យ ដើម្បីបញ្ចូលបច្ចេកវិទ្យាទៅក្នុងការអនុវត្តការបង្រៀនរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។ លើសពីនេះ និស្សិតនៅតាមសាកលវិទ្យាល័យទាំងនេះអាចមានលទ្ធភាពមានកម្រិតក្នុងការចូលប្រើប្រាស់ធនធានឌីជីថល រួមទាំងបណ្ណាល័យអនឡាញ មូលដ្ឋានទិន្នន័យស្រាវជ្រាវ និងកម្មវិធីសូហ្វវែរអប់រំ។ ភាពមិនស៊ីគ្នាលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការបណ្តុះបណ្តាលសាស្ត្រាចារ្យ និងលទ្ធភាពរបស់សិស្សក្នុងការចូលប្រើប្រាស់ធនធានឌីជីថល អាចមានផលប៉ះពាល់យ៉ាងខ្លាំងលើលទ្ធផលសិក្សា និងឱកាសនៅក្នុងប្រទេសកម្ពុជា។ និស្សិតនៅតាមសាកលវិទ្យាល័យ

ដែលមានគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលទំនើប អាចទទួលបានអត្ថប្រយោជន៍ពីបទពិសោធន៍សិក្សាល្អប្រសើរ មានលទ្ធភាពចូលប្រើប្រាស់ធនធានអប់រំកាន់តែទូលំទូលាយ និងមានឱកាសកាន់តែច្រើនសម្រាប់ការសហការ និងនវានុវត្តន៍។ ម្យ៉ាងវិញទៀត និស្សិតនៅតាមសាកលវិទ្យាល័យដែលមានហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងធនធានមានកម្រិត អាចជួបប្រទះបញ្ហាប្រឈមនៅក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព និងទទួលបានជំនាញឌីជីថលដែលចាំបាច់ដើម្បីទទួលបានជោគជ័យនៅក្នុងកម្លាំងពលកម្មនៅសតវត្សទី21 នេះ។ ដើម្បីដោះស្រាយភាពមិនស៊ីគ្នាទាំងនេះ កម្ពុជាចាំបាច់ត្រូវផ្តោតអាទិភាពការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ផ្តល់ការគាំទ្រសម្រាប់ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍សាស្ត្រាចារ្យ ព្រមទាំងលើកកម្ពស់កិច្ចសហការ និងការចែករំលែកចំណេះដឹងក្នុងចំណោមសាកលវិទ្យាល័យនានា។ តាមរយៈការបណ្តុះវប្បធម៌នវានុវត្តន៍ និងឧត្តមភាពឌីជីថលនៅទូទាំងវិស័យអប់រំ កម្ពុជាអាចធានាបានថានិស្សិតទាំងអស់មានលទ្ធភាពទទួលបានការអប់រំមានគុណភាព និងឱកាសទទួលបានជោគជ័យនៅក្នុងយុគសម័យឌីជីថល។




*រូបភាព 19៖ ការដោះស្រាយគម្លាតបរិវត្តកម្មឌីជីថលនៅប្រទេសកម្ពុជា*

### 9.2.3 ប្រទេសម៉ាឡេស៊ី

សាកលវិទ្យាល័យ Universiti Teknologi Malaysia (UTM) មានភាពលេចធ្លោរជាងគេលើគំនិតផ្តួចផ្តើមបដិវត្តន៍ឌីជីថលនៅក្នុងប្រទេសម៉ាឡេស៊ី ដោយទាញយកប្រយោជន៍ពីបច្ចេកវិទ្យាទំនើប ដើម្បីពង្រឹងសមត្ថភាពបង្រៀន សិក្សា និងស្រាវជ្រាវ។ គំនិតផ្តួចផ្តើមសាលាឆ្លាតវៃ មន្ទីរពិសោធន៍នវានុវត្តន៍ឌីជីថល និងកិច្ចសហការនៅក្នុងវិស័យរបស់សាកលវិទ្យាល័យ UTM បានកំណត់ជំហរសាកលវិទ្យាល័យនេះជាសាកលវិទ្យាល័យឈានមុខគេ នៅក្នុងការបញ្ចូល

បច្ចេកវិទ្យាទៅក្នុងការអប់រំឧត្តមសិក្សា។ ទោះជាយ៉ាងនេះក្តី គំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលទំនើប បានគូសបញ្ជាក់ពីគម្លាតដ៏ធំ បើប្រៀបធៀបទៅនឹងសាកលវិទ្យាល័យម៉ាឡេស៊ីផ្សេងៗទៀត ដែលអាចនឹងខ្វះការខិតខំប្រឹងប្រែងផ្នែកឌីជីថល។ គ្រឹះស្ថានអប់រំទាំងនេះ អាចជួបប្រទះនឹងបញ្ហាប្រឈមដូចជា មូលនិធិមានកម្រិតសម្រាប់ការដំឡើងសមត្ថភាពបច្ចេកវិទ្យា ថ្នាក់ដឹកនាំខ្វះចក្ខុវិស័យដើម្បីធ្វើបរិវត្តកម្មឌីជីថល និងភាពជាដៃគូមានកម្រិតជាមួយនឹងភាគីពាក់ព័ន្ធក្នុងវិស័យ និងរដ្ឋាភិបាល។

ភាពជោគជ័យរបស់សាកលវិទ្យាល័យ UTM គឺជាសមិទ្ធផលមកពីវិធីសាស្ត្របុរេសកម្មរបស់ខ្លួនចំពោះបរិវត្តកម្មឌីជីថល ថ្នាក់ដឹកនាំប្រកបដោយចក្ខុវិស័យ និងភាពជាដៃគូយុទ្ធសាស្ត្រជាមួយក្រុមហ៊ុនឈានមុខគេក្នុងវិស័យ និងក្រុមហ៊ុនបច្ចេកវិទ្យា។ តាមរយៈការវិនិយោគលើបច្ចេកវិទ្យាទំនើប ការផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រដល់សាស្ត្រាចារ្យ និងការដាក់បញ្ចូលបច្ចេកវិទ្យា និងការបណ្តុះវប្បធម៌នវានុវត្តន៍ និងសហគ្រិនភាព សាកលវិទ្យាល័យ UTM អាចមានលទ្ធភាពឈានមុខគេជានិច្ចនៅក្នុងការអប់រំឌីជីថល។

# 10 អនុសាសន៍

អនុសាសន៍ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ សង្កត់ធ្ងន់អំពីសារៈសំខាន់នៃយុទ្ធសាស្ត្រសម្របសម្រួលតាមស្ថានភាព និងតម្រូវការពិសេសៗរបស់ប្រទេសនីមួយៗ ដោយធានាបានថាកិច្ចខិតខំប្រឹងប្រែងបរិវត្តកម្មឌីជីថលមានប្រសិទ្ធភាព និងមានចីរភាព។ ខាងក្រោមនេះ គឺជារបៀប សម្រួលអនុសាសន៍សម្រាប់ក្រុមភាគីពាក់ព័ន្ធនីមួយៗនៅក្នុងប្រទេសឡាវ កម្ពុជា និងម៉ាឡេស៊ី៖




*រូបភាព 20៖ ប្រទេសឡាវ*

## 10.1 សម្រាប់រដ្ឋាភិបាល

ដើម្បីគាំទ្រដល់បរិវត្តកម្មឌីជីថលនៅក្នុងការអប់រំឧត្តមសិក្សា រដ្ឋាភិបាលត្រូវអនុវត្តគោលនយោ បាយ និងយុទ្ធសាស្ត្រផ្តល់មូលនិធិដែលសម្របតាមតម្រូវការពិសេសរបស់វិស័យ៖

### 10.1.1 ប្រទេសឡាវ

i. បង្កើតក្របខណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ ដែលសម្របតាមតម្រូវការ និងបញ្ហាប្រឈមជាក់លាក់នៃការអប់រំឧត្តមសិក្សានៅប្រទេសឡាវ ដោយផ្តល់អាទិភាពលើបរិវត្តកម្មឌីជីថល។

ii. បង្កើតយន្តការផ្តល់មូលនិធិប្រកបដោយចីរភាព ជាពិសេសសម្រាប់ការដំឡើងសមត្ថភាពបច្ចេកវិទ្យា ការបណ្តុះបណ្តាលសាស្ត្រាចារ្យ និងមជ្ឈមណ្ឌលនវានុវត្តន៍នៅក្នុងគ្រឹះស្ថានអប់រំឧត្តមសិក្សា។

iii. បន្ទឺដំណើរការបទប្បញ្ញត្តិ និងផ្តល់ការលើកទឹកចិត្តសម្រាប់សាកលវិទ្យាល័យនានាឱ្យប្រកាន់យកបច្ចេកវិទ្យាថ្មីៗ និងគរុកោសល្យបង្រៀនប្រកបដោយភាពច្នៃប្រឌិត។

iv. បណ្តុះភាពជាដៃគូរវាងរដ្ឋ និងឯកជន ដើម្បីទាញយកប្រយោជន៍ពីជំនាញ និងធនធាន សម្រាប់គំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលប្រកបដោយភាពជោគជ័យ។

v. អនុវត្តគំនិតផ្តួចផ្តើមអក្ខរកម្មឌីជីថលជាតិ ដើម្បីធានាថានិស្សិត សាស្ត្រាចារ្យ និង បុគ្គលិករដ្ឋបាលទទួលបានការបំពាក់បំប៉នជំនាញចាំបាច់នានា ដើម្បីប្រឡូកក្នុងវិស័យ ឌីជីថលប្រកប ដោយប្រសិទ្ធភាព។

### 10.1.2ប្រទេសកម្ពុជា

i. អនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រផ្តល់មូលនិធិដែលដោះស្រាយបញ្ហាប្រឈម និងឱកាសពិសេសនៅក្នុងការអប់រំឧត្តមសិក្សា ជាពិសេសពាក់ព័ន្ធនឹងបរិវត្តកម្មឌីជីថល។

ii. ធានាឱ្យមានយន្តការផ្តល់មូលនិធិប្រកបដោយចីរភាព ដើម្បីគាំទ្រដល់ការបញ្ចូលបច្ចេកវិទ្យា ការអភិវឌ្ឍសាស្ត្រាចារ្យ និងនវានុវត្តន៍នៅក្នុងគ្រឹះស្ថានអប់រំឧត្តមសិក្សា។

iii. បន្ស៊ីដំណើរការបទប្បញ្ញត្តិ ដើម្បីសម្របសម្រួលដល់នវានុវត្តន៍ និងកិច្ចសហការរវាង សាកលវិទ្យាល័យនានា និងដៃគូក្នុងវិស័យ។

iv. ជំរុញភាពជាដៃគូរវាងរដ្ឋនិងឯកជន ដើម្បីជំរុញគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថល និងលើក កម្ពស់ការចែករំលែកចំណេះដឹង និងកិច្ចសហការ។

v. វិនិយោគលើគំនិតផ្តួចផ្តើមអក្ខរកម្មឌីជីថលជាតិ ដើម្បីបំពាក់បំប៉នភាគីពាក់ព័ន្ធនូវជំនាញ ឌីជីថល ដែលចាំបាច់ដើម្បីទទួលបានជោគជ័យនៅក្នុងសេដ្ឋកិច្ចឌីជីថល។

## ប្រទេសម៉ាឡេស៊ីៈ

vi. បន្តគាំទ្រគ្រឹះស្ថានអប់រំជាន់ខ្ពស់ នៅក្នុងការបញ្ចូលបច្ចេកវិទ្យាទៅក្នុងការបង្រៀន ការសិក្សា និងដំណើរការរដ្ឋបាលតាមរយៈក្របខណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ។

vii. ធានាឱ្យបាននូវយន្តការផ្តល់មូលនិធិប្រកបដោយចីរភាពសម្រាប់ការដំឡើងសមត្ថភាពបច្ចេកវិទ្យា ការអភិវឌ្ឍសាស្ត្រាចារ្យ និងមជ្ឈមណ្ឌលនវានុវត្តន៍ ដើម្បីជំរុញបរិវត្តកម្មឌីជីថល។

viii. បន្តបន្ស៊ីដំណើរការបទប្បញ្ញត្តិ និងផ្តល់ការលើកទឹកចិត្តសម្រាប់សាកលវិទ្យាល័យនានា ដើម្បីនវានុវត្តន៍ និងសហការជាមួយដៃគូក្នុងវិស័យ។

ix. ពង្រឹងភាពជាដៃគូរវាងរដ្ឋនិងឯកជន ដើម្បីទាញយកប្រយោជន៍ពីធនធាន និងជំនាញសម្រាប់គំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលប្រកបដោយភាពជោគជ័យ។

x. ពង្រីកគំនិតផ្តួចផ្តើមអក្ខរកម្មឌីជីថលជាតិ ដើម្បីធានាថានិស្សិត សាស្ត្រាចារ្យ និងបុគ្គលិករដ្ឋបាលទទួលបានការបំពាក់បំប៉នជំនាញឌីជីថលចាំបាច់នានា ដើម្បីទទួលបានជោគជ័យក្នុងវិស័យឌីជីថល។




*រូបភាព 20៖ ប្រទេសកម្ពុជា*

## 10.2 សម្រាប់គ្រឹះស្ថានអប់រំឧត្តមសិក្សា៖

គ្រឹះស្ថានអប់រំឧត្តមសិក្សា ដើរតួនាទីដ៏សំខាន់នៅក្នុងការជំរុញបរិវត្តកម្មឌីជីថល។ ខាងក្រោមនេះ គឺជាអនុសាសន៍មួយចំនួនសម្រាប់ការអនុវត្តយកបច្ចេកវិទ្យា គរុកោសល្យបង្រៀន និងដំណើរការរដ្ឋបាលថ្មីៗ៖

### 10.2.1 ប្រទេសឡាវ

i. បណ្តុះវប្បធម៌នវានុវត្តន៍ និងការពិសោធន៍នៅក្នុងគ្រឹះស្ថានអប់រំឧត្តមសិក្សា ដើម្បីជំរុញបរិវត្តកម្មឌីជីថល។

ii. វិនិយោគលើកម្មវិធីអភិវឌ្ឍសាស្ត្រាចារ្យ ដើម្បីកសាងសមត្ថភាពឌីជីថលក្នុងចំណោមអ្នកអប់រំ និងលើកកម្ពស់ការរួមបញ្ចូលបច្ចេកវិទ្យានៅក្នុងការបង្រៀន និងការសិក្សា។

iii. កែសម្រួលកម្មវិធីសិក្សា ដើម្បីបញ្ចូលជំនាញឌីជីថល និងសមត្ថភាពឌីជីថល ដោយត្រៀមរៀបចំនិស្សិតសម្រាប់កម្លាំងពលកម្មឌីជីថល។

iv. បែងចែកធនធានសម្រាប់ការជំឡើងសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងពង្រឹងសេវាគាំទ្រសម្រាប់អ្នកសិក្សាឌីជីថល។

v. ជំរុញកិច្ចសហប្រតិបត្តិការអន្តរវិស័យ ដើម្បីដោះស្រាយបញ្ហាប្រឈមស្មុគស្មាញ និងលើកកម្ពស់ដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត។

### 10.2.2 ប្រទេសកម្ពុជា

i. ជំរុញវប្បធម៌នវានុវត្តន៍ និងការស្វែងយល់បច្ចេកវិទ្យាថ្មីៗនៅក្នុងគ្រឹះស្ថានអប់រំឧត្តមសិក្សា។

ii. វិនិយោគលើកម្មវិធីអភិវឌ្ឍសាស្ត្រាចារ្យ ដើម្បីកសាងសមត្ថភាពឌីជីថលក្នុងចំណោមអ្នកអប់រំ និងលើកកម្ពស់ការសិក្សាពង្រឹងដោយបច្ចេកវិទ្យា។

iii. កែលម្អកម្មវិធីសិក្សា ដើម្បីដាក់បញ្ចូលជំនាញឌីជីថល និងការអនុវត្តជាក់ស្តែងនៃបច្ចេកវិទ្យា ដោយត្រៀមលក្ខណៈនិស្សិតសម្រាប់ឱកាសអនាគត។

iv. ផ្តល់អាទិភាពការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងសេវាគាំទ្រ ដើម្បីថានិស្សិតគ្រប់រូបអាចចូលទៅប្រើប្រាស់ធនធានបានដោយរលូន។

v. បង្កើតបរិយាកាសសិក្សាដែលមានការគាំទ្រ ដែលបណ្តុះនូវកិច្ចសហការ ការចូលរួម និងសុខុមាលភាពក្នុងចំណោមនិស្សិត និងសាស្ត្រាចារ្យ។

### 10.2.3 ប្រទេសម៉ាឡេស៊ី

i. បន្តលើកកម្ពស់វប្បធម៌នវានុវត្តន៍ និងសហគ្រិនភាពនៅក្នុងគ្រឹះស្ថានអប់រំឧត្តមសិក្សា ដើម្បីជំរុញបរិវត្តកម្មឌីជីថល។

ii. វិនិយោគលើកម្មវិធីអភិវឌ្ឍសាស្ត្រាចារ្យ ដើម្បីពង្រឹងសមត្ថភាពឌីជីថល និងលើកកម្ពស់ការបញ្ចូលបច្ចេកវិទ្យានៅក្នុងការបង្រៀន និងការសិក្សា។

iii. ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា ដើម្បីរួមបញ្ចូលជំនាញ និងសមត្ថភាពឌីជីថល ដោយធានាថានិស្សិតបានត្រៀមខ្លួនរួចរាល់សម្រាប់សេដ្ឋកិច្ចឌីជីថល។

iv. បែងចែកធនធានសម្រាប់ការដំឡើងសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងពង្រីកសេវាគាំទ្រសម្រាប់អ្នកសិក្សាឌីជីថល។

v. ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរវិស័យ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើងថ្មីៗ និងលើកកម្ពស់ដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត។




*រូបភាព 21៖ ប្រទេសម៉ាឡេស៊ី*

## 10.3 សម្រាប់ដៃគូអន្តរជាតិ និងម្ចាស់ជំនួយ

អង្គការអន្តរជាតិ និងម្ចាស់ជំនួយមានតួនាទីដ៏សំខាន់នៅក្នុងការគាំទ្រដល់បរិវត្តកម្មឌីជីថលនៅក្នុងតំបន់។ ខាងក្រោមនេះ គឺជាអនុសាសន៍មួយចំនួនសម្រាប់ការចូលរួមរបស់ដៃគូទាំងអស់៖

### 10.3.1 ប្រទេសឡាវ

i. ផ្តល់មូលនិធិ ជំនួយបច្ចេកទេស និងជំនាញ ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថល នៅក្នុងគ្រឹះស្ថានអប់រំឧត្តមសិក្សា។

ii. សម្របសម្រួលការចែករំលែកចំណេះដឹង និងកិច្ចសហការរវាងដៃគូអន្តរជាតិ ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធក្នុងស្រុក ដើម្បីជំរុញបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសឡាវ។

iii. កៀរគរធនធាន និងជំរុញកិច្ចខិតខំប្រឹងប្រែងដែលមានការសម្របសម្រួល ដើម្បីពង្រីកឥទ្ធិពល និងចីរភាពនៃគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសឡាវឱ្យដល់កម្រិតអតិបរិមា។

iv. គាំទ្រដល់ការស្រាវជ្រាវ និងគំនិតផ្តួចផ្តើមនវានុវត្តន៍ដែលទាញយកប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល ដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗនៅក្នុងការអប់រំឧត្តមសិក្សានៅក្នុងប្រទេសឡាវ។

v. បង្កើតក្របខណ្ឌតាមដាន និងវាយតម្លៃ ដើម្បីតាមដានឥទ្ធិពលនៃការវិនិយោគលើបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសឡាវ និងផ្តល់ព័ត៌មានអំពីការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើភស្តុតាង។

### 10.3.2 ប្រទេសកម្ពុជា

i. ផ្តល់មូលនិធិ ជំនួយបច្ចេកទេស និងជំនាញ ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថល នៅក្នុងគ្រឹះស្ថានអប់រំឧត្តមសិក្សានៅកម្ពុជា។

ii. សម្របសម្រួលការចែករំលែកចំណេះដឹង និងកិច្ចសហការរវាងដៃគូអន្តរជាតិ ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធក្នុងស្រុក ដើម្បីជំរុញបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសកម្ពុជា។

iii. កៀរគរធនធាន និងជំរុញកិច្ចខិតខំប្រឹងប្រែងដែលមានការសម្របសម្រួល ដើម្បីពង្រីកឥទ្ធិពល និងចីរភាពនៃគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសកម្ពុជាឱ្យដល់កម្រិតអតិបរិមា។

iv. គាំទ្រដល់ការស្រាវជ្រាវ និងគំនិតផ្តួចផ្តើមនវានុវត្តន៍ដែលទាញយកប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល ដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗនៅក្នុងការអប់រំឧត្តមសិក្សានៅក្នុងប្រទេសកម្ពុជា។

v. បង្កើតក្របខណ្ឌតាមដាន និងវាយតម្លៃ ដើម្បីតាមដានឥទ្ធិពលនៃការវិនិយោគលើបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសកម្ពុជា និងផ្តល់ព័ត៌មានអំពីការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើភស្តុតាង។

### 10.3.3 ប្រទេសម៉ាឡេស៊ី

i. ផ្តល់មូលនិធិ ជំនួយបច្ចេកទេស និងជំនាញ ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថល នៅក្នុងគ្រឹះស្ថានអប់រំឧត្តមសិក្សានៅប្រទេសម៉ាឡេស៊ី។

ii. សម្របសម្រួលការចែករំលែកចំណេះដឹង និងកិច្ចសហការរវាងដៃគូអន្តរជាតិ ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធក្នុងស្រុក ដើម្បីជំរុញបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសម៉ាឡេស៊ី។

iii. កៀរគរធនធាន និងជំរុញកិច្ចខិតខំប្រឹងប្រែងដែលមានការសម្របសម្រួល ដើម្បីពង្រីកឥទ្ធិពល និងចីរភាពនៃគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសម៉ាឡេស៊ីឱ្យដល់កម្រិតអតិបរិមា។

iv. គាំទ្រដល់ការស្រាវជ្រាវ និងគំនិតផ្តួចផ្តើមនវានុវត្តន៍ដែលទាញយកប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល ដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗនៅក្នុងការអប់រំឧត្តមសិក្សានៅក្នុងប្រទេសម៉ាឡេស៊ី។

v. បង្កើតក្របខណ្ឌតាមដាន និងវាយតម្លៃ ដើម្បីតាមដានឥទ្ធិពលនៃការវិនិយោគលើបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសម៉ាឡេស៊ី និងផ្តល់ព័ត៌មានពីការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើភស្តុតាង។




*រូបភាព 22៖ ប្រទេសម៉ាឡេស៊ី*

# 11 ការចូលរួម និងការរំពឹងទុក

សាកលវិទ្យាល័យ University of Granada អាចដើរតួនាទីនាំមុខ និងប្រកបឥទ្ធិពលនៅក្នុងការពន្លឿនបរិវត្តកម្មឌីជីថលសម្រាប់គ្រឹះស្ថានឧត្តមសិក្សានៅអាស៊ីអាគ្នេយ៍។ ដើម្បីកិច្ចការនេះបាន សាកលវិទ្យាល័យអាចប្រើប្រាស់ទិន្នន័យដែលប្រមូលបានពីការស្ទង់មតិនិស្សិត និងបុគ្គលិកនៅតាមបណ្តាសាកលវិទ្យាល័យនៅតាមប្រទេសដូចជា កម្ពុជា ឡាវ និងម៉ាឡេស៊ី ដើម្បីជាព័ត៌មាន និងសម្របជាយុទ្ធសាស្ត្រទៅនឹងគំនិតផ្តួចផ្តើមរបស់សាកលវិទ្យាល័យ។ ខាងក្រោមនេះគឺជាវិធីសាស្ត្រ ជាក់លាក់ដែលសាកលវិទ្យាល័យ University of Granada អាចពិចារណាពីការពង្រីកឥទ្ធិពលរបស់ខ្លួននៅក្នុងផ្នែកនេះបាន៖

**ការស្រាវជ្រាវលម្អិត និងការវិភាគទិន្នន័យ៖** មុនពេលរៀបចំបង្កើតគំនិតផ្តួចផ្តើមជាក់លាក់ណាមួយ ជាការសំខាន់ណាស់ដែលសាកលវិទ្យាល័យ University of Granada ត្រូវអនុវត្តការវិភាគលម្អិតលើទិន្នន័យដែលប្រមូលបានពីការស្ទង់មតិ។ កិច្ចការនេះរួមបញ្ចូលមិនត្រឹមតែការត្រួតពិនិត្យលទ្ធផលបូកសរុបប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការបើកកកាយលម្អិតទៅលើលំនាំ និងបម្រែបម្រួលដែលមានស្រាប់តាមប្រទេស គ្រឹះស្ថាន និងក្រុមប្រជាសាស្ត្រ។ តាមរយៈការយល់ដឹងកាន់តែច្បាស់អំពីតម្រូវការ និងបញ្ហាប្រឈមជាក់លាក់ដែលបានកំណត់រកឃើញនៅ

ក្នុងបរិបទនីមួយៗ សាកលវិទ្យាល័យ University of Granada នឹងមានជំហរកាន់តែរឹងមាំក្នុងការរៀបចំកិច្ចអន្តរាគមន៍ដែលមានប្រសិទ្ធភាព និងស្របតាមបរិបទ។

**ការអភិវឌ្ឍកម្មវិធីសាកល្បងសម្របតាមតម្រូវការ៖** ជាជាងការអនុវត្តយកវិធីសាស្ត្រមួយត្រូវទាំងអស់សម្រាប់តំបន់ទាំងមូល សាកលវិទ្យាល័យ University of Granada អាចពិចារណាអនុវត្តកម្មវិធីសាកល្បងដែលសម្របតាមតម្រូវការ និងបរិបទពិសេសតាមប្រទេស និងសាកលវិទ្យាល័យនីមួយៗនៅអាស៊ីអាគ្នេយ៍។ កម្មវិធីសាកល្បងទាំងនេះអាចផ្តោតលើផ្នែកនានាដែលបានកំណត់រកឃើញជាអាទិភាពនៅក្នុងការស្ទង់មតិ ដូចជាការបណ្តុះបណ្តាលគ្រូបង្រៀនអំពីបច្ចេកវិទ្យាអប់រំ ការបង្កើតមាតិកាឌីជីថល និងការធ្វើឱ្យប្រសើរឡើងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យានៅក្នុងសាកលវិទ្យាល័យ។




*រូបភាព 23៖ ការចូលរួម និងការរំពឹងទុក*

ការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ បន្ថែមពីលើការផ្តល់ជូនកម្មវិធីបណ្តុះបណ្តាលដំបូង សាកលវិទ្យាល័យ University of Granada អាចបង្កើតកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់សាស្ត្រាចារ្យ និងបុគ្គលិករដ្ឋបាលនៅអាស៊ីអាគ្នេយ៍។ ការអភិវឌ្ឍនេះអាចរួមមានឱកាសសិក្សាតាមប្រព័ន្ធអនឡាញ សិក្ខាសាលាផ្ទាល់ និងការហាត់ការនៅសាកលវិទ្យាល័យ University of Granada ឬគ្រឹះស្ថានអប់រំឌីជីថលអឺរ៉ុបឈានមុខគេផ្សេងៗទៀត។ តាមរយៈការបង្កើតវិធីសាស្ត្រសិក្សាពេញមួយជីវិត វិធីសាស្ត្រនេះធានាថាជំនាញឌីជីថល និងសមត្ថភាពរបស់អ្នកអប់រំ គឺមានបច្ចុប្បន្នភាពជានិច្ច និងស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។

**ការបណ្តុះកិច្ចសហការ និងការចែករំលែកចំណេះដឹង៖** សាកលវិទ្យាល័យ University of Granada អាចដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសម្របសម្រួលកិច្ចសហការ និងការផ្លាស់ប្តូរចំណេះដឹងទៅវិញទៅមករវាងគ្រឹះស្ថានអប់រំនៅអាស៊ីអាគ្នេយ៍ និងអឺរ៉ុប។ តួនាទីនេះអាចរួមមានការបង្កើតភាពជាដៃគូផ្លាស់ប្តូរនិស្សិត និងការសិក្សាផ្លូវការ ការរៀបចំសិក្ខាសាលា និង

សន្និសីទអន្តរជាតិ ព្រមទាំងការបង្កើតបណ្តាញអ្នកជំនាញដែលផ្តោតលើការអប់រំឌីជីថល។ តាមរយៈការលើកកម្ពស់កិច្ចសន្ទនា និងកិច្ចសហការរវាងភាគីពាក់ព័ន្ធខុសៗគ្នា ល្បឿនបរិវត្តកម្មឌីជីថលនៅក្នុងតំបន់អាចពន្លឿនទៅបាន។




*រូបភាព 24៖ កិច្ចសហការ និងការចែករំលែកចំណេះដឹង*

**ការវាយតម្លៃ និងមតិត្រលប់ជាប្រចាំ៖** ជាចុងក្រោយ ជាការសំខាន់ណាស់ដែលសាកលវិទ្យាល័យ University of Granada បង្កើតយន្តការវាយតម្លៃ និងមតិត្រលប់រឹងមាំ ដើម្បីតាមដានត្រួតពិនិត្យវឌ្ឍនភាព និងសម្របសម្រួលយុទ្ធសាស្ត្រតាមការចាំបាច់។ យន្តការនេះរួមបញ្ចូលមិនត្រឹមតែការអនុវត្តការវាយតម្លៃឥទ្ធិពលតាមពេលកំណត់ក្នុងន័យលទ្ធផលសិក្សា និងការពេញចិត្តរបស់និស្សិតប៉ុណ្ណោះទេ តែថែមទាំងការប្រមូលមតិត្រលប់ និងសំណូមពរជាប់ជាប្រចាំពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់ដែលចូលរួមនៅក្នុងដំណើរការនេះ។ តាមរយៈការអនុវត្តយកវិធីសាស្ត្រស្ទួន និងផ្តោតលើអ្នកប្រើប្រាស់ សាកលវិទ្យាល័យ University of Granada អាចធានាបានថាគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថល គឺមានប្រសិទ្ធភាព មានចីរភាព និងមានការផ្លាស់ប្តូរពិតប្រាកដ។




*រូបភាព 25៖ **ការវាយតម្លៃ និងមតិត្រលប់ជាប្រចាំ***

តាមរយៈការប្រមូលព័ត៌មាននេះ សាកលវិទ្យាល័យ University of Granada មានសមត្ថភាព និងធនធានក្នុងការបំពេញតួនាទីនាំមុខគេនៅក្នុងការពន្លឿនបរិវត្តកម្មឌីជីថលសម្រាប់ការអប់រំឧត្តមសិក្សានៅអាស៊ីអាគ្នេយ៍។ តាមរយៈការទាញប្រយោជន៍ពីទិន្នន័យដែលប្រមូលបានពីការស្ទង់មតិ និងការអនុវត្តយកវិធីសាស្ត្រប្រកបដោយយុទ្ធសាស្ត្រ និងតាមបរិបទ សាកលវិទ្យាល័យ University of Granada អាចរួមចំណែកបានយ៉ាងធំធេងលើការអភិវឌ្ឍការអប់រំឌីជីថលឱ្យកាន់តែទំនើបនៅក្នុងតំបន់ ដែលការអភិវឌ្ឍនេះជួយលើកកម្ពស់គុណភាពអប់រំ និងលទ្ធភាពចូលសិក្សានៅឧត្តមសិក្សាសម្រាប់មនុស្សជំនាន់ក្រោយនៅអាស៊ីអាគ្នេយ៍។

# 12 សេចក្តីសន្និដ្ឋាន

អាស៊ីអាគ្នេយ៍ មានភាពលេចធ្លោរលើបដិវត្តយ៉ាងរហ័សនៅក្នុងវិស័យអប់រំឧត្តមសិក្សា ដែលជំរុញដោយទំនើបកម្មឌីជីថលលឿន។ នៅពេលដែលបណ្តាប្រទេសនៅទូទាំងតំបន់ចាប់យកឱកាសពីនវានុវត្តន៍បច្ចេកវិទ្យា អនាគតនៃការអប់រំឧត្តមសិក្សា គឺជាអនាគតមួយដែលកំណត់ដោយកម្រិតនៃភាពងាយស្រួល បត់បែន និងនវានុវត្តន៍ដែលមិនធ្លាប់មានពីមុនមក។

ទិសដៅបរិវត្តកម្មឌីជីថលនៅក្នុងការអប់រំឧត្តមសិក្សា នាំមកនូវយុគសម័យថ្មីនៃការសិក្សា ជាយុគសម័យមួយដែលការដាក់កំហិតប្រពៃណីត្រូវបានលុបបំបាត់ចោល ហើយឱកាសសម្រាប់ការរីកចម្រើន និងការអភិវឌ្ឍគឺមានកាន់តែច្រើន។ បច្ចេកវិទ្យាបង្កើតឡើងថ្មីៗ ដូចជាបញ្ញាសិប្បនិម្មិត ពិភពនិម្មិត និងប្លុកឆេន (blockchain) គឺជំរុញដល់ការអភិវឌ្ឍវិធីសាស្ត្រគរុកោសល្យ ដែលអាចសម្រេចទៅបានបទពិសោធន៍សិក្សាតាមតម្រូវការ ដែលសម្របតាមតម្រូវការ និងចំណូលចិត្តរបស់និស្សិតម្នាក់ៗ។ លើសពីនេះ បច្ចេកវិទ្យាទាំងនេះផ្តល់នូវវេទិកាថ្មីសម្រាប់កិច្ចសហការ ការស្រាវជ្រាវ និងការតភ្ជាប់ទំនាក់ទំនងជាសកល ដោយបង្កើតបានជាប្រព័ន្ធសិក្សាចម្រុះ ដែលលុបបំបាត់ឧបសគ្គភូមិសាស្ត្រលែងមានតទៅទៀត។

ជាការពិតណាស់ យើងបន្ថែមសេចក្តីសន្និដ្ឋានដើម្បីផ្តល់នូវទិដ្ឋភាពកាន់តែគ្រប់ជ្រុងជ្រោយអំពីរបកគំហើញ និងអនុសាសន៍៖

ជារួម ការវាយតម្លៃតម្រូវការ និងការវិភាគប្រៀបធៀប បានផ្តល់នូវទស្សនៈដ៏មានតម្លៃអំពីទិដ្ឋភាពបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសឡាវ កម្ពុជា និងម៉ាឡេស៊ី ដោយគូសបញ្ជាក់អំពីទាំងបញ្ហាប្រឈមទូទៅ និងឱកាសពិសេសដែលគ្រឹះស្ថានអប់រំឧត្តមសិក្សាជួបប្រទះនៅក្នុងប្រទេសនីមួយៗ។ តាមរយៈការសំយោគចំណុចសំខាន់ៗដែលបានលើកឡើងនៅទូទាំងការវិភាគនេះ ប្រធានបទ និងអនុសាសន៍លេចធ្លោរមួយចំនួនបានបង្ហាញឡើង ដោយសង្កត់ធ្ងន់

អំពីសារៈសំខាន់នៃយុទ្ធសាស្ត្រសម្របសម្រួល ភាពជាដៃគូសហការ និងការប្តេជ្ញាចិត្តជាប្រចាំចំពោះបរិវត្តកម្មឌីជីថលនៅក្នុងការអប់រំឧត្តមសិក្សា។

ទីមួយ ការវិភាគនេះបញ្ជាក់ឱ្យឃើញអំពីតួនាទីដ៏សំខាន់របស់រដ្ឋាភិបាលក្នុងនាមជាអ្នកជំរុញសំខាន់នៃបរិវត្តកម្មឌីជីថល។ នៅទូទាំងប្រទេសឡាវ កម្ពុជា និងម៉ាឡេស៊ី រដ្ឋាភិបាលដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់គោលនយោបាយបរិស្ថាន ការបែងចែកធនធាន និងការផ្តល់ការគាំទ្រផ្នែកបទប្បញ្ញត្តិដែលចាំបាច់សម្រាប់ការពន្លឿនគំនិតផ្តួចផ្តើមឌីជីថលលនៅក្នុងការអប់រំឧត្តមសិក្សា។ របកគំហើញលើកឡើងថា ក្របខណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ យន្តការមូលនិធិប្រកបដោយចីរភាព កំណែទម្រង់បទប្បញ្ញត្តិ និងគំនិតផ្តួចផ្តើមអន្តរកម្មឌីជីថល គឺសុទ្ធតែជាសមាសធាតុដ៏សំខាន់នៃកិច្ចខិតខំប្រឹងប្រែងដឹកនាំដោយរដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើងនូវនវានុវត្តន៍ឌីជីថល និងការរីកចម្រើនលើវិស័យអប់រំឧត្តមសិក្សា។ តាមរយៈការកំណត់អាទិភាពលើផ្នែកទាំងនេះ និងការបន្សុីគោលនយោបាយជាមួយតម្រូវការ និងបរិបទជាក់លាក់របស់ប្រទេសនីមយួៗ រដ្ឋាភិបាលអាចបង្កើតបានជាបរិយាកាសអំណោយផលដល់បរិវត្តកម្មឌីជីថល។

ទីពីរ ការវាយតម្លៃតម្រូវការគូសបញ្ជាក់អំពីតួនាទីដ៏សំខាន់របស់គ្រឹះស្ថានអប់រំឧត្តមសិក្សាក្នុងនាមជាអ្នកជំរុញបរិវត្តកម្មឌីជីថល និងជាភ្នាក់ងារនាំមកនូវការផ្លាស់ប្តូរនៅក្នុងប្រព័ន្ធអប់រំរបស់គ្រឹះស្ថាននីមួយៗ។ គ្រឹះស្ថានអប់រំត្រូវតែរួមបញ្ចូលបច្ចេកវិទ្យា និងនវានុវត្តន៍ វិនិយោគលើកម្មវិធីអភិវឌ្ឍសាស្ត្រាចារ្យ ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា ដើម្បីឆ្លុះបញ្ចាំងអំពីសមត្ថភាពឌីជីថល ដំឡើងសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងពង្រឹងសេវាគាំទ្រនិស្សិត ដើម្បីបណ្តុះវប្បធម៌នៃការសិក្សាឌីជីថល និងនវានុវត្តន៍។ លើសពីនេះទៅទៀត ការវិភាគនេះគូសបញ្ជាក់អំពីសារៈសំខាន់នៃការបន្សុីយុទ្ធសាស្ត្ររបស់គ្រឹះស្ថានអប់រំជាមួយនឹងអាទិភាពជាតិ និងការលើកកម្ពស់ភាពជាដៃគូជាមួយវិស័យ រដ្ឋាភិបាល និងអង្គការអន្តរជាតិ ដើម្បីពង្រីកឥទ្ធិពល និងចីរភាពឱ្យដល់កម្រិតអតិបរិមា។

ជាងនេះទៅទៀត សេចក្តីសន្និដ្ឋាននេះសង្កត់ធ្ងន់អំពីសារៈសំខាន់នៃភាពជាដៃគូអន្តរជាតិ និងការគាំទ្ររបស់ម្ចាស់ជំនួយនៅក្នុងការពន្លឿនកិច្ចខិតខំប្រឹងប្រែងបរិវត្តកម្មឌីជីថល។ គំនិតផ្តួចផ្តើមសហការជាមួយដៃគូអន្តរជាតិ និងភាគីពាក់ព័ន្ធមូលដ្ឋាន អាចសម្របសម្រួលដល់ការកៀរគរធនធាន ការចែករំលែកចំណេះដឹង ការកសាងសមត្ថភាព និងការសហការស្រាវជ្រាវ ដែលតាមរយៈការសហការនេះជួយពង្រីកឥទ្ធិពលនៃគំនិតផ្តួចផ្តើមឌីជីថលសម្រាប់ការអប់រំឧត្តមសិក្សា។ តាមរយៈការលើកកម្ពស់ជំនាញ ធនធាន និងបណ្តាញដៃគូអន្តរជាតិ ប្រទេសឡាវ កម្ពុជា និងម៉ាឡេស៊ី អាចជម្នះបញ្ហាប្រឈមកាន់តែមានប្រសិទ្ធភាព និងសម្រេចបាននូវវឌ្ឍនភាព

កាន់តែធំធេងឆ្ពោះទៅរកការកសាងប្រព័ន្ធអប់រំឧត្តមសិក្សាកាន់តែមានបរិយាប័ន្ន នវានុវត្តន៍ និងឌីជីថល។

ជាការសំខាន់ណាស់ សេចក្តីសន្និដ្ឋាននេះអះអាងជាថ្មីម្តងទៀតអំពីសារៈសំខាន់នៃការអនុវត្តយកវិធីសាស្ត្រចម្រុះ និងជាក់លាក់តាមបរិបទចំពោះបរិវត្តកម្មឌីជីថល ដោយទទួលស្គាល់អំពីតម្រូវការ បញ្ហាប្រឈម និងឱកាសចម្រុះគ្នាដែលមាននៅក្នុងប្រទេសឡាវ កម្ពុជា និងម៉ាឡេស៊ី។ តាមរយៈការអនុវត្តយុទ្ធសាស្ត្រសម្របតាមតម្រូវការ ការបណ្តុះភាពជាដៃគូសហការ និងការរក្សាការប្តេជ្ញាចិត្តរយៈពេលយូរចំពោះនវានុវត្តឌីជីថល ភាគីពាក់ព័ន្ធនានាអាចចូលរួមពន្លឿនគោលបំណងរួមនៃការបង្កើតវិស័យអប់រំឧត្តមសិក្សាដែលត្រៀមរួចរាល់សម្រាប់អនាគត ដែលជំរុញដល់អ្នកសិក្សា ជំរុញកំណើនសេដ្ឋកិច្ច និងបណ្តុះឱ្យមានការអភិវឌ្ឍសង្គមនៅអាស៊ីអាគ្នេយ៍។

# 13 សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះអស់ពីចិត្តចំពោះក្រុមការងារគម្រោងបរិវត្តកម្មឌីជីថលនៅអាស៊ីអាគ្នេយ៍ (DX.SEA) ចំពោះការគាំទ្រ និងកិច្ចសហការដ៏មានតម្លៃនៅក្នុងការសម្រេចបាននូវរបាយការណ៍។ ការរួមចំណែករបស់ក្រុមការងារ ពិតជាមានសារៈសំខាន់ណាស់នៅក្នុងការអភិវឌ្ឍ និងការបញ្ចប់គម្រោងនេះដោយជោគជ័យ។ យើងខ្ញុំសូមផ្តល់នូវការទទួលស្គាល់ជាពិសេសដល់អ្នករៀបចំគម្រោងបរិវត្តកម្មឌីជីថលនៅអាស៊ីអាគ្នេយ៍ (DX.SEA) ចំពោះការលះបង់ និងការដឹកនាំរបស់ពួកគេនៅក្នុងការសម្របសម្រួលដល់កិច្ចខិតខំប្រឹងប្រែងរួមគ្នានេះ។ ចក្ខុវិស័យ និងការប្តេជ្ញាចិត្តរបស់ពួកគេ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់នៃការងារនេះ ហើយយើងខ្ញុំពិតជាអរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែង និងការលះបង់មិននឿយហត់របស់ក្រុមការងារ។ យើងខ្ញុំសូមថ្លែងអំណរគុណដល់សមាជិកក្រុមការងារ DX.SEA ទាំងអស់ចំពោះការខិតខំប្រឹងប្រែងបំពេញការងារ ការសហការ និងការគាំទ្រនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនេះ។ វិជ្ជាជីវៈ និងការលះបង់របស់ក្រុមការងារ គឺពិតជាសំខាន់ណាស់ ហើយយើងខ្ញុំពិតជាអរគុណចំពោះឱកាសក្នុងការធ្វើការងាររួមគ្នាលើគម្រោងដ៏សំខាន់នេះ។ យើងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកគ្រប់គ្នាដែលបានចូលរួមចំណែកតាមមធ្យោបាយផ្សេងៗគ្នាដល់ការរៀបចំរបាយការណ៍នេះ។ ការប្តេជ្ញាចិត្ត និងការលះបង់របស់ក្រុមការងារ បានធ្វើឱ្យរបាយការណ៍នេះអាចរៀបចំឡើងបាន ហើយយើងខ្ញុំទន្ទឹងរង់ចាំបន្តកិច្ចសហការនេះចំពោះគម្រោងនាពេលអនាគត ដើម្បីជំរុញបរិវត្តិកម្មឌីជីថលនៅអាស៊ីអាគ្នេយ៍ និងតំបន់ផ្សេងៗ។

# 14 ឯកសារយោង


Subramaniam, G. (ឆ្នាំ2008)។ ការជម្នះក្តីបារម្ភនៅអាស៊ីនៅក្នុងការឱ្យអ្នកសិក្សាចូលរួមនៅក្នុងការអប់រំតាមប្រព័ន្ធអនឡាញ។ ការសិក្សាអំពីការអប់រំអន្តរជាតិ 1(4), 10-18។

Ahmad, T. (ឆ្នាំ2020)។ វិធីសាស្រ្តផ្អែកលើសេណារីយ៉ូដើម្បីកំណត់ចក្ខុវិស័យអនាគតឡើងវិញនៃការអប់រំជាន់ខ្ពស់ ដែលត្រៀមរៀបចំនិស្សិតសម្រាប់អនាគតការងារ។ ការអប់រំជាន់ខ្ពស់ ជំនាញ និងការសិក្សាផ្អែកលើការងារ 10(1), 217-238។

Hanna, N. K. (ឆ្នាំ2010)។ ការធ្វើបរិវត្តកម្មរដ្ឋាភិបាល និងការកសាងសង្គមព័ត៌មាន៖ បញ្ហាប្រឈម និងឱកាសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។

Sharma, A. V. N. S., Jayalakshmi, S., Tripathy, A., Katekhaye, D., & Sharma, A. (ឆ្នាំ2024)។ ការស្វែងរកវិធីសាស្រ្តគរុកោសល្យប្រកបដោយភាពច្នៃប្រឌិតសម្រាប់ពង្រឹងការចូលរួមរបស់និស្សិត។ ការធ្វើសេចក្តីសម្រេចចិត្ត៖ ការអនុវត្តការគ្រប់គ្រង និងវិស្វកម្ម 8(1), 175-188។

Boca, G. D. (ខែមីនា ឆ្នាំ2013)។ គំរូ ADKAR ធៀបនឹងការផ្លាស់ប្តូរការគ្រប់គ្រងគុណភាព។ នៅក្នុងសន្និសិទអន្តរជាតិហានិភ័យនៃសេដ្ឋកិច្ចសហសម័យ មហាវិទ្យាល័យសេដ្ឋកិច្ច និងគ្រប់គ្រងធុរកិច្ច សាកលវិទ្យាល័យ Dunarea de Jos University of Galati៖ Galati រូម៉ានី។

Singh, A. (ឆ្នាំ2013)។ ការសិក្សាអំពីតួនាទីនៃក្របខណ្ឌ 7S របស់ McKinsey នៅក្នុងការសម្រេចបាននូវឧត្តមភាពស្ថាប័ន។ ទិន្នានុប្បវត្តិអភិវឌ្ឍស្ថាប័ន 31(3), 39។

Romrell, D., Kidder, L., & Wood, E. (ឆ្នាំ2014)។ គំរូ SAMR ជាក្របខណ្ឌសម្រាប់ការវាយតម្លៃ mLearning។ ទិន្នានុប្បវត្តិសិក្សាតាមប្រព័ន្ធអនឡាញ 18(2), 39។

Chaphichith, X. (ឆ្នាំ2014)។ ការប្រែប្រួលលើអភិបាលកិច្ច និងការគ្រប់គ្រងគ្រឹះស្ថានអប់រំឧត្តមសិក្សានៅប្រទេសឡាវ៖ សាកលវិទ្យាល័យជាតិឡាវ (និក្ខេបបទបណ្ឌិត Universidade do Minho (ព័រទុយហ្គាល់))។

សែន វិចិត្រ និង រស់ សុវាចា។ "រចនាសម្ព័ន្ធអភិបាលកិច្ចអប់រំឧត្តមសិក្សានៅកម្ពុជា"។ (ឆ្នាំ2013)។

Madhur, S. (ឆ្នាំ2014)។ គម្លាតជំនាញនៅកម្ពុជា៖ លក្ខណៈនៃបញ្ហា និងជម្រើសគោលនយោបាយ។ វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា។

Hashim, A., & Leitner, G. (ឆ្នាំ2014)។ អង់គ្លេសជាភាសាគោលនៅក្នុងការអប់រំឧត្តមសិក្សានៅម៉ាឡេស៊ី។ ទិន្នានុប្បវត្តិអាស៊ីស្តីពីភាសាសាស្រ្តអនុវត្ត 1(1), 16-27។

Lee, M. N. (ឆ្នាំ2007)។ ការអប់រំឧត្តមសិក្សានៅអាស៊ីអាគ្នេយ៍នៅយុគសម័យសាកលភាវូបនីយកម្ម។ នៅក្នុងសៀវភៅណែនាំអន្តរជាតិស្តីពីការអប់រំឧត្តមសិក្សា (ទំព័រ. 539-555)។ Dordrecht៖ Springer ហូឡង់។

Un, L., & Sok, S. (ឆ្នាំ2018)។ ប្រព័ន្ធ និងគ្រឹះស្ថានអប់រំឧត្តមសិក្សានៅកម្ពុជា។ ការអប់រំឧត្តមសិក្សា 70, 80។

Ariffin, A. S., & Mahdzir, A. M. (ឆ្នាំ2021)។ ការអភិវឌ្ឍ និងសមិទ្ធផលនៃគោលនយោបាយវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍នៅបណ្តាប្រទេសនៅអាស៊ាន៖ ការវិភាគប្រៀបធៀបនៃប្រទេសម៉ាឡេស៊ីក្នុងដំណាក់កាលអន្តរកាលធៀបជាមួយនឹងប្រទេសមីយ៉ាន់ម៉ា កម្ពុជា និងឡាវនៅក្នុងដំណាក់កាលអភិវឌ្ឍន៍។ ទិន្នានុប្បវត្តិគោលនយោបាយវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ 7(1), 56-61។

Inui, M. (ឆ្នាំ 2020)។ ការលើកកម្ពស់លទ្ធភាព និងគុណភាពអប់រំនៅសាធារណរដ្ឋប្រជាមានិតឡាវ ផ្អែកលើគោលការណ៍ទាំងប្រាំពីរនៃសេចក្តីប្រកាសស្តីពីកុមារបោះបង់ការសិក្សានៅអាស៊ាន។ ទិន្នានុប្បវត្តិស្តីពីការសិក្សានៅឡាវ 1(1), 75-98។

Sa-ngiamwibool, A., & Wisaeng, K. (ឆ្នាំ2022)។ ឥទ្ធិពលនៃសហគមន៍សេដ្ឋកិច្ចអាស៊ានលើធុរកិច្ចអប់រំនៅបណ្តាប្រទេសនៅអាស៊ាន៖ ការវិភាគប្រៀបធៀបឆ្លងប្រទេស (សារណាបណ្ឌិតសាកលវិទ្យាល័យ Mahasarakham University)។

Sol, K. (ឆ្នាំ2021)។ ការគិតគូរឡើងវិញអំពីការអប់រំឧត្តមសិក្សានៅកម្ពុជា។ បញ្ហាប្រឈម និងឱកាសសហសម័យក្រោយសម័យកូវីដ-19។ ទិន្នានុប្បវត្តិស្តីពីការអប់រំអន្តរជាតិ 27, 46-60។

Apriliyanti, I. D., Kusumasari, B., Pramusinto, A., & Setianto, W. A. (ឆ្នាំ2021)។ គម្លាតឌីជីថលនៅប្រទេសជាសមាជិកអាស៊ី៖ ការវិភាគកត្តាសំខាន់ៗសម្រាប់កម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិកប្រកបដោយជោគជ័យ។ ការពិនិត្យឡើងវិញលើព័ត៌មានអនឡាញ 45(2), 440-460។

Aung, S. W., & Aye, T. T. (ឆ្នាំ2024)។ ការអនុវត្ត និងភាពផ្ទុយគ្នានៃគោលនយោបាយអប់រំ និងការអនុវត្តនៃគ្រឹះស្ថានអប់រំឧត្តមសិក្សានៅតំបន់ត្រីកោណមាស (អាស៊ីអាគ្នេយ៍)៖ ការជាប់ទាក់ទិនសម្រាប់ការអភិវឌ្ឍអន្តរជាតិ។ អនាគតគោលនយោបាយក្នុងវិស័យអប់រំ 14782103241229520។

Yoshino, F. (ឆ្នាំ2021)។ បរិវត្តកម្មធុរកិច្ចអាស៊ី៖ ពីឧស្សាហូបនីយកម្មដល់បរិវត្តកម្មឌីជីថល។ ការគ្រប់គ្រងសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបរិយាប័ន្ននៅក្នុងការធ្វើបរិវត្តកម្មអាស៊ី 1-23។

Rana, P. B., Ji, X., Rana, P. B., & Ji, X. (ឆ្នាំ2020)។ BRI និងអាស៊ីអាគ្នេយ៍។ គំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវរបស់ចិន៖ ឥទ្ធិពលលើអាស៊ី និងរបៀបវារៈគោលនយោបាយ 93-111។

Sapuan, N. M., & Roly, M. R. (ឆ្នាំ2021)។ ឥទ្ធិពលនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងការវិនិយោគផ្ទាល់ពីបរទេស ជាកត្តាជំរុញដល់កំណើនសេដ្ឋកិច្ចនៅប្រទេសអាស៊ានបូក 8៖ ការវិភាគអំពី panel regression៖ ទិន្នានុប្បវត្តិអន្តរជាតិស្តីពីការគ្រប់គ្រងឧស្សាហាកម្ម 9, 91-98។

Voinea, I. (ឆ្នាំ2020)។ ប្រព័ន្ធសេវាធនាគារនៃសេដ្ឋកិច្ចកើតឡើងថ្មីនៅអាស៊ីធៀបទៅនឹងប្រវត្តិនៃជំងឺកូវីដ-19។ ករណីសិក្សា៖ តំបន់អាស៊ាន។ ទិន្នានុប្បវត្តិស្តីពីការសិក្សាហិរញ្ញវត្ថុ 5(9), 134-146។